Jesus Film Project®
A Cru Ministry

# ពិចារណាអំពី
# ព្រះយេស៊ូវ

## យុទ្ធសាស្ត្រ១០សប្តាហ៍សម្រាប់
## ក្រុមតូចនៅក្នុងសហគមន៍



# ពិចារណាអំពីព្រះយេស៊ូវ

## យុទ្ធសាស្ត្រ១០សប្តាហ៍សម្រាប់ក្រុមតូចនៅក្នុងសហគមន៍

*ការប្រើខ្សែភាពយន្ត ម៉ាកុស ជាឡាង ការដោះឱ្យរួចពីភាពអាម៉ាស់ ដើម្បីជួយមនុស្សឱ្យកាន់តែងាយយល់ថា តើព្រះយេស៊ូវជានរណា និងការដើរតាមព្រះអង្គមានន័យយ៉ាងដូចម្តេច?*

Jesus Film Project®
A Cru Ministry

## មគ្គុទេសក៍អ្នកដឹកនាំ

# ព្រះជាម្ចាស់នឹងប្រើអ្នកស្របតាមគោលបំណងដើម្បីសាងសង់នគររបស់ទ្រង់នៅក្នុងសហគមន៍របស់អ្នក។

សូមចំណាយពេលបន្តិចដើម្បីរំលឹក នៅពេលអ្នករៀនអំពីព្រះយេស៊ូវជានរណា ក្តីមេត្តា ក្តីបរិសុទ្ធ និងភាពទន់ភ្លន់របស់ទ្រង់ ព្រមទាំងភាពស្មោះត្រង់របស់ទ្រង់ជាមុនសិន។ ព្រះអង្គជាក្តីសង្ឃឹមគ្រប់យ៉ាង សម្រាប់អ្នក និងជាអ្វីគ្រប់យ៉ាងដែលអាចសង្គ្រោះ និងរំដោះអ្នក។ ព្រះអង្គជាក្តីសង្ឃឹមរបស់អ្នក ហើយព្រះអង្គជាក្តីសង្ឃឹមរបស់ប្រជាជាតិទាំងអស់ និងមនុស្សទាំងអស់។

សាវកយ៉ូហានសរសេរនៅក្នុងកណ្ឌវិវរណៈថា៖

«ក្រោយនោះមក ខ្ញុំមើលទៅឃើញមនុស្សច្រើនកុះករ ដែលគ្មានអ្នកណាអាចរាប់បានឡើយ គេមកពីគ្រប់ជាតិសាសន៍ គ្រប់កុលសម្ព័ន្ធ គ្រប់ប្រជាជន និងគ្រប់ភាសា ឈរនៅមុខបល្ល័ង្ក និងនៅមុខកូនចៀម ទាំងពាក់អាវសវែង ហើយដៃកាន់ធាងចាក។ គេបន្លឺសំឡេងយ៉ាងខ្លាំងថា៖ «ការសង្គ្រោះស្រេចលើព្រះនៃយើង ដែលគង់លើបល្ល័ង្ក និងស្រេចលើកូនចៀម!» (វិវរណៈ ៧:៩-១០, គកស១៦)។

ការកាន់ខ្ជាប់នូវចំណេះដឹងអំពីស្តេចលើអស់ទាំងស្តេចជានរណា ហើយយើងចង់ពង្រឹងអ្នក ដើម្បីចែកចាយដល់អ្នកដទៃទៀត ហើយរីកចម្រើនជាមួយគ្នានៅក្នុងគ្រួសាររបស់ព្រះជាម្ចាស់។

ព្រះយេស៊ូវមានបន្ទូលនៅក្នុងខចុងក្រោយនៃដំណឹងល្អលោកម៉ាថាយថា៖

«ដូច្នេះ ចូរទៅបង្កើតឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ហើយបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្តីដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ហើយមើល៍ ខ្ញុំក៏នៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់គ្រាចុងបំផុត» អាម៉ែន (ម៉ាថាយ ២៨:១៩-២០, គកស១៦)។

ព្រះអង្គប្រាប់យើងឱ្យចេញទៅ បង្កើតសិស្ស ធ្វើពិធីជ្រមុជទឹកឱ្យគេ ហើយថាព្រះអង្គនឹងគង់នៅជាមួយយើងជានិច្ច សូមចូលរួមជាមួយយើង មិនថាតាមជ្រលងភ្នំ ឬនៅកំពូលភ្នំខ្ពស់ក្តី។ *ពិចារណាអំពីព្រះយេស៊ូវ* ផ្តល់នូវយុទ្ធសាស្ត្រដ៏អស្ចារ្យដើម្បីជួយ។ ប្រើប្រាស់វាដើម្បីអ្នកអាចជួយពង្រឹងសិស្សដែលប្តូរផ្តាច់ ដែលប្រើប្រាស់ជីវិតរបស់ពួកគេជាមួយគ្នា ខណៈដែលរៀនឱ្យកាន់តែស៊ីជម្រៅអំពីព្រះយេស៊ូវជានរណា។

*ពិចារណាអំពីព្រះយេស៊ូវ* ប្រើវគ្គនៃខ្សែភាពយន្ត *ម៉ាកដាឡា៖ ការដោះឱ្យរួចពីភាពអាម៉ាស់* ដែលរៀបរាប់អំពីរឿងរ៉ាវរបស់ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរ តាមរយៈការមើលឃើញផ្ទាល់ភ្នែករបស់នាងម៉ារាម៉ាកដាឡាតាមរយៈទីបន្ទាល់របស់នាង។ នេះគឺជាឧបករណ៍ដ៏អស្ចារ្យមួយ ក្នុងការប្រើនៅក្នុងក្រុមតូច រៀបចំឡើងនៅក្នុងគ្រួសារ មិត្តសំឡាញ់ និងសូម្បីតែនៅជាមួយអ្នកស្គាល់គ្នាក្តី។ នៅពេលដែលពួកគេបានទស្សនាវគ្គមួយនៃសាច់រឿងហើយ អ្នកចូលរួមអាចរៀនបន្ថែមអំពីជីវិត ការអស្ចារ្យ ការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ។ មានការជាច្រើនដែលនឹងជំរុញយើង ដើម្បីឱ្យបានដើរតាមព្រះយេស៊ូវ ដោយព្រោះព្រះអង្គគឺជាព្រះអង្គ។ ចំណែកអ្នកផ្សេងទៀត គេនឹងមានឱកាសបន្ថែមទៀតដើម្បីរៀនអំពីទ្រង់។ នៅចុងបញ្ចប់នៃស៊េរី *ពិចារណាអំពីព្រះយេស៊ូវ* នឹងផ្តល់ការអញ្ជើញអ្នកផ្សេងទៀតឱ្យចូលរួមក្នុងក្រុមតូច ពិភាក្សាដោយប្រើ មិនថា *វីកា* ឬ *ការស្គាល់ព្រះយេស៊ូវ* ជាឧបករណ៍ដែលបានបង្កើតឡើងដោយផលិតកម្មខ្សែភាពយន្តអំពីព្រះយេស៊ូវ ®។

មានជំហានសាមញ្ញបួនក្នុងការប្រើ *ពិចារណាអំពីព្រះយេស៊ូវ*

# ជំពូកទី១ ០១

## កំណត់ថា តើអ្នកចង់ឈោងចាប់អ្នកណា

តើអ្នកណាដែលអ្នកចង់ឱ្យគេស្គាល់ព្រះយេស៊ូវថែមទៀត? តើមាននរណានៅក្បែរភូមិ ឬអ្នកជិតខាងរបស់អ្នកដែលអ្នកចង់ឱ្យគេស្គាល់ទ្រង់? ក្រុមមិត្តសំឡាញ់ ឬអ្នកធ្វើការជាមួយ?

ទីមួយ ស្វែងរក «មនុស្សនៃក្តីសុខសាន្ត» នៅទីនោះ។ នៅក្នុងលូកា ១០:៦ ព្រះយេស៊ូវបានចាត់អ្នកដើរតាមព្រះអង្គ៧២នាក់ ដើម្បីនាំព្រះបន្ទូលរបស់ទ្រង់ ព្រះអង្គបានបង្គាប់ពួកគេឱ្យស្វែករកមនុស្សនៃក្តីសុខសាន្តនៅគ្រប់កន្លែងពួកគេទៅជួបនឹងអ្នកនោះ។

មនុស្សនៃក្តីសុខសាន្តគឺជាមនុស្ស មិនចាំបាច់ថា អ្នកនោះជាអ្នកជឿនោះទេ អ្នកនោះគឺ៖

- ជាមនុស្សដែលបើកចំហសម្រាប់ព្រះគ្រីស្ទ និងសេចក្តីបង្រៀនរបស់ទ្រង់។
- ជាមនុស្សដែលមានឥទ្ធិពល ឬជាមនុស្សដែលល្បីឈ្មោះនៅក្នុងសហាគមន៍
- គឺអ្នកដែលព្រម និងរួចរាល់ដើម្បីណែនាំអ្នកទៅកាន់បណ្តាញរបស់ពួកគេនៅក្នុងសហាគមន៍ដែលអ្នកបានជ្រើសរើស។
- ជាមនុស្សដែលព្រមជួយអ្នកក្នុងការអញ្ជើញអ្នកដទៃទៀតដើម្បីមកចូលរួម និងទស្សនាខ្សែភាពយន្ត *ម៉ាកដាឡា*

យើងណែនាំថា អ្នកត្រូវកសាងទំនាក់ទំនងជាមួយអ្នកនេះសិន។ អ្នកអាចប្រើដំណាក់កាលបីនេះជាឧបករណ៍ណែនាំដើម្បីជួយបណ្តុះទំនាក់ទំនងរបស់អ្នកជាមួយមនុស្សនៃក្តីសុខសាន្តរបស់អ្នក។

**ក. អធិស្ឋាន**
អធិស្ឋានសម្រាប់មនុស្សនៃក្តីសុខសាន្តនេះ។ អធិស្ឋានសូមព្រះជាម្ចាស់បង្ហាញអ្នកថា តើនរណាជាមនុស្សដែលនឹងណែនាំអ្នកទៅកាន់គ្រួសារ និងមិត្តសំឡាញ់របស់ពួកគេ។ នៅពេលអ្នកចាប់ផ្តើមស្គាល់អ្នកនេះហើយ ចូរសួរគេថា តើអ្នកអាចអធិស្ឋានឱ្យពួកគេបានយ៉ាងដូចម្តេច។

**ខ. ការថែទាំ**
នៅពេលអ្នកអធិស្ឋានសម្រាប់មិត្តថ្មីនេះហើយ ហើយចាប់ផ្តើមដឹងពីរសេចក្តីត្រូវការរបស់ពួកគេ ចូរបង្ហាញថា អ្នកយកចិត្តទុកដាក់ជាមួយពួកគេ ដោយការស្តាប់ និងបំពេញសេចក្តីត្រូវការទាំងនោះ។ ចូរធ្វើជាមិត្តល្អ និងជាមិត្តដែលគាំទ្រ។

**គ. ការចែកចាយ**
នៅពេលយើងបានស្តាប់គេហើយ ហើយបំពេញសេចក្តីត្រូវការគេហើយ គេបានផ្តល់អភ័យឯកសិទ្ធិដើម្បីចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវដល់យើងហើយ។ នៅពេលមានឱកាសហើយ ចូរចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវ និងការអត់ទោសរបស់ទ្រង់ជាមួយមនុស្សនៃក្តីសុខសាន្ត ប្រសិនបើ គេមិនទាន់ស្គាល់ព្រះអង្គនៅឡើយ។

# ជំហានទីពីរ ០២

## បង្ហាញ ម៉ាដាឡា៖ ការដោះឱ្យរួចពីភាពអាម៉ាស់

សម្រាប់យុទ្ធសាស្ត្រនេះ យើងនឹងប្រើក្រុមស្ត្រីជាឧទាហរណ៍របស់យើង ប៉ុន្តែ បុរស និងគ្រួសារក៏យើងត្រូវស្វាគមន៍ ហើយលើកទឹកចិត្តឱ្យប្រើ *ពិចារណាអំពីព្រះយេស៊ូវ* ដែរ!

ជាមួយមនុស្សនៃក្ដីសុខសាន្តរបស់អ្នក ចូរអញ្ជើញស្ត្រីផ្សេងៗដើម្បីទស្សនារឿង *ម៉ាកដាឡា*, ប្រហែលនៅផ្ទះរបស់មនុស្សដែលស្រឡាញ់ក្ដីសុខសាន្ត។ បន្ទាប់ពី ទស្សនាខ្សែភាពយន្តហើយ ប្រកបអាហារ ឬផ្តល់ជូនជាអាហារ ឬភេសជ:ខ្លះក៏បាន។ ការយកចិត្តទុកដាក់ជាមួយអ្នកដែលចូលរួម ទទួលភ្ញៀវដោយចៅរ៉ៅ ពាក់ទាក់ផងដែរ។

អ្នកអាចចូលទៅកាន់ *ម៉ាកដាឡា* ដោយឥតបង់ថ្លៃនៅឯ គេហទំព័រ ផលិតកម្មខ្សែភាពយន្តរបស់ព្រះយេស៊ូវ កម្មវិធីខ្សែភាពយន្តរបស់ព្រះយេស៊ូវ ដែលមានច្រើនជា២០០ភាសា។ ប្រសិនបើ អ្នកភ្ជាប់ជាមួយទូរទស្សន៍តាមរយ: USB ដោយប្រើ Flash drive ដើម្បីមើល *ម៉ាកដាឡា*។ ប្រសិនបើ អ្នកមានថេបប្លេត និងឧបករណ៍ដើម្បីភ្ជាប់ជាមួយធុងបាស់ប្ល៊ូធូស អ្នកអាចមើលខ្សែភាពយន្តជាមួយក្រុមតូចដែលអាចមានគ្នារហូតដល់១០នាក់ ឬអាចច្រើនជាងនេះនៅក្នុងបរិយាកាសធំជាង។

ពេលមើលខ្សែភាពយន្តចប់ សូមផ្តល់ជូនការអញ្ជើញពីរដល់អ្នកទស្សនា សម្រាប់ការចូលរួមបន្ថែមទៀត។

ទីមួយ អញ្ជើញស្ត្រីទាំងនោះឱ្យបានត្រឡប់ជាអ្នកដើរតាមព្រះយេស៊ូវ។ ចូរពិចារណាពីការចែកចាយរឿងរ៉ាវផ្ទាល់ខ្លួនរបស់អ្នក និងទាក់ទងជាមួយនឹងការនោះ ជាមួយនឹងសាច់រឿងដែលពួកគេបានទស្សនា។

ទីពីរ អញ្ជើញពួកគេឱ្យត្រឡប់មកវិញនៅថ្ងៃបន្ទាប់ ដើម្បីជជែកអំពីព្រះយេស៊ូវបន្ថែមទៀត! លើកទឹកចិត្តពួកគេឱ្យនាំមិត្តសំឡាញ់ ដែលចាប់អារម្មណ៍នឹងការនេះផងដែរ។ ធ្វើដូច្នេះ អ្នកអាចឆ្លើយសំណួរផ្សេងៗ ខណ:ពេលដែលចាប់ផ្តើមសិក្សាសាច់រឿងរបស់ព្រះគ្រីស្ទតាមរយ: កម្មវិធីសិក្សា *ពិចារណាអំពីព្រះយេស៊ូវ។*

បន្ទាប់មក ចំណាយពេលដើម្បីស្គាល់ស្ត្រីដែលបានចូលរួមទាំងនោះ។ សាច់រឿង និងប្រធានបទដែលពួកគេបានឃើញនៅក្នុងសាច់រឿងអាចនឹងកើតមានឡើងនៅក្នុងជីវិតរបស់ពួកគេផ្ទាល់ផងដែរ ដែលជាការឈឺចាប់។ ចូរអធិស្ឋានសម្រាប់ពួកគេម្នាក់ៗ ប្រសិនបើ ពួកគេត្រូវការការអធិស្ឋាន។

ឥឡូវនេះ ចូលមកដល់ចំណុចដ៏ល្អបំផុតហើយ!

# ជំពូកទីបី ០៣

## ចាប់ផ្ដើមសាច់រឿងថ្មី ពិចារណាអំពីព្រះយេស៊ូវ ជាមួយក្រុមតូចនៅក្នុងសហគមន៍

អធិស្ឋានសម្រាប់ស្ត្រីម្នាក់ៗ ដែលបានបង្ហាញពីការចាប់អារម្មណ៍អំពីព្រះយេស៊ូវ និងក្រុមតូច សូមឱ្យដីនៃដួងចិត្តរបស់នាង មានសភាពល្អ ហើយព្រះវិញ្ញាណបរិសុទ្ធអាចបំផ្លាស់បំប្រែបាន។ អធិស្ឋានសូមឱ្យសាច់រឿងរបស់ព្រះយេស៊ូវបានប៉ះពាល់ដល់ពួកគេយ៉ាងខ្លាំង និងក្នុងរបៀបដែលមានន័យ ហើយថាពួកគេអាចផ្សាភ្ជាប់នឹងសាច់រឿងដោយផ្ទាល់។

នៅក្នុងការជួបជុំនេះ និងការជួបជុំដែលនឹងមកដល់នៅពេលបន្ទាប់ អ្នកនឹងប្រើ ១០វគ្គចេញពីខ្សែភាពយន្ត *ម៉ាកដាឡា* ដើម្បីរៀនបន្ថែមអំពីព្រះយេស៊ូវ និងដើម្បីជជែកអំពីព្រះអង្គជាមួយគ្នា។ នេះគឺជាប្រធានបទទូទៅសម្រាប់វគ្គនីមួយៗ៖

១. ស្ត្រីម្នាក់ៗបានទស្សនា និងស្គាល់
២. ព្រះយេស៊ូវ៖ លើសពីហោរាម្នាក់
៣. រំដោះឱ្យរួចពីចំណង
៤. សេចក្ដីស្រឡាញ់របស់ព្រះយេស៊ូវ
៥. ជម្លោះ និងការរើសអើង
៦. ការព្យាបាល និងការស្ដារឡើងវិញ
៧. ភាពអាម៉ាស់ និងកិត្តិយស
៨. ការស្គាល់ព្រះយេស៊ូវ និងការអត់ទោសរបស់ព្រះអង្គ
៩. ប្រាថ្នាចង់ទទួលព្រះយេស៊ូវ និងចែកចាយអំពីព្រះយេស៊ូវ
១០. រស់នៅជាមួយព្រះយេស៊ូវ

សម្រាប់វគ្គសិក្សានៅសប្ដាហ៍បន្ទាប់ ក្រុមថ្មីរបស់អ្នកនឹងរីកចម្រើននៅក្នុងការយល់ដឹងអំពីព្រះយេស៊ូវគ្រីស្ទ និងអ្វីទៅដែលជាអ្នកដើរតាមព្រះអង្គ។ ពួកគេនឹងមានឱកាសដើម្បីមានបទពិសោធនៅក្នុងសហគមន៍គ្រីស្ទបរិស័ទនៅក្នុងជីវិត។

សម្រាប់គ្រប់ពេលជួបជុំ យើងប្រើអ្វីដែលហៅថាបីលើបី (៣/៣) ជាទម្រង់ដើម្បីចម្រើនរឹងមាំក្នុងទំនាក់ទំនងមិត្តភាព។ ទម្រង់ ៣/៣ គឺជារចនាសម្ព័ន្ធក្រុមដែលមានប្រសិទ្ធភាព ក្នុងការផ្ដល់លំហូរងាយស្រួល និងទម្លាប់សម្រាប់ការជួបជុំ និងរក្សានូវគោលបំណង ការលើកទឹកចិត្ត និងការលូតលាស់របស់អ្នក។ វាមានបីផ្នែក៖ ការមើលត្រឡប់ក្រោយ ការមើលទៅលើ និងការមើលទៅមុខ។

កំណត់ចំណាំ៖ *ការពិចារណាអំពីព្រះយេស៊ូវ* គឺត្រូវបានបង្កើតឡើងដើម្បីជាគំរូក្នុងការជួយអ្នកដើម្បីសម្រេចការត្រាស់ហៅរបស់ព្រះ។ **សូមកុំភ័យខ្លាចនឹងកែសម្រួលការនេះដើម្បីឱ្យស៊ីនឹងសេចក្ដីត្រូវការនៃបរិបទរបស់អ្នក!**

# បីលើបី

ដំណើរការហ្វឹកហ្វឺនសិស្ស

## ការមើលក្រោយ

- **ការថែទាំ៖** ចែកចាយពីសុខទុក្ខរបស់អ្នក។ ចែកចាយពីសាច់រឿងក្នុងជីវិត និងជីវប្រវត្តិរបស់អ្នក។
- **ថ្វាយបង្គំព្រះ៖** ចែកចាយពីអ្វីដែលអ្នកបានអនុវត្តពីអ្វីដែលអ្នកបានរៀន។
- **សាទរភាពស្មោះត្រង់៖** ចែកចាយពីរបៀបដែលអ្នកអនុវត្តអ្វីដែលអ្នកកំពុងរៀន។
- **ការចាប់យកនិមិត្ត៖** ចែកចាយពីរបៀបដែលព្រះយេស៊ូវអាចផ្លាស់ប្តូរជីវិតរបស់អ្នក។ លើកទឹកចិត្តគ្នាទៅវិញទៅមក។

## ការមើលទៅលើ

- **បង្ហាញ៖** ទស្សនាវគ្គនីមួយៗពីរដង។ រៀនសាច់រឿងថ្មីអំពីព្រះយេស៊ូវជាមួយគ្នា។
- **ប្រាប់៖** ចូរឱ្យនរណាម្នាក់ប្រាប់វគ្គនៃសាច់រឿងដោយសំដីរបស់នាងផ្ទាល់។
- **បញ្ចប់ហើយ៖** អញ្ជើញអ្នកផ្សេងទៀតឱ្យនិយាយបន្ថែមសាច់រឿងដែលខ្វះចន្លោះ។
- **ពិភាក្សា៖** ចូរពិភាក្សាឱ្យបានច្រើនតាមរយៈសំនួរពិភាក្សាស្របតាមពេលវេលាដែលមាន។

## ការមើលទៅមុខ

- **ការប្រព្រឹត្តតាម៖** ប្តូរផ្តាច់ពីរបៀបដែលអ្នកនឹងអនុវត្តតាមអ្វីដែលអ្នកបានរៀន។
- **ការអនុវត្ត៖** ប្រាប់សាច់រឿងដល់គ្នាទៅវិញទៅមក។
- **ចែកចាយ៖** ពិភាក្សាថាតើអ្នកនឹងប្រាប់រឿងនេះទៅកាន់នរណា។
- **អធិស្ឋាន៖** អរគុណដល់ព្រះជាម្ចាស់សម្រាប់អ្វីដែលយើងបានរៀន។ អធិស្ឋានសម្រាប់គ្នាទៅវិញទៅមក និងអ្នកដទៃទៀតនៅក្នុងសហគមន៍។

# ជំហានទីបួន

# ០៤

## ឈោះជំហានបន្ទាប់

កាលពីមេរៀនមុន *ពិចារណាអំពីព្រះយេស៊ូវ* នឹងពិភាក្សាអំពីជីវិតរស់នៅរបស់គ្រីស្ទបរិស័ទ។ នៅក្នុងវគ្គនេះ នាងម៉ារាំរលឹកពីការត្រាស់ហៅ និងការបង់ថ្លៃនៃការដើរតាមព្រះយេស៊ូវ។ វាគឺជាការសំខាន់ដើម្បីណែនាំមនុស្សម្នាក់នៅក្នុងក្រុមរបស់អ្នកក្នុងការឆ្ពោះទៅរកជំហានបន្ទាប់ ប្រសិនបើ ពួកគេរួចរាល់។ **ការនេះអាចជាឱកាសដ៏អស្ចារ្យក្នុងការលើកទឹកចិត្តនរណាម្នាក់ ឬមនុស្សជាច្រើននាក់នៅក្នុងសមាជិកក្រុមរបស់អ្នក ដើម្បីចាប់ផ្តើមក្រុម ដោយខ្លួនគេផ្ទាល់ ពិចារណាអំពីព្រះយេស៊ូវ និងចែកចាយអ្វីដែលពួកគេបានរកឃើញជាមួយអ្នកដទៃទៀត។** ប្រសិនបើអ្នកចង់បន្តជួបជុំជាមួយគ្នា យើងសូមណែនាំឱ្យប្តូរទៅក្រុមថ្មី ដូចជា *វីកា* ឬ *ស្គាល់ព្រះយេស៊ូវ។* អ្នកអាចស្វែងរកបន្ថែមទៀតបានទាំងពីរនៅក្នុងការសិក្សាខាងក្រោម៖

*វីកា* ទំព័រព័ត៌មាន
www.jesusfilm.org/partners/resources/strategies/women/gather-and-grow/

*ការស្គាល់ព្រះយេស៊ូវ* ទំព័រព័ត៌មាន
www.jesusfilm.org/partners/resources/strategies/knowing-jesus/

*ការស្គាល់ព្រះយេស៊ូវ* វីដេអូនៃការផ្សព្វផ្សាយ
www.youtube.com/watch?v=MkYpNK5OvKk

# មគ្គុទេសក៍អំណះអំណាងណែនាំរហ័សរបស់អ្នកដឹកនាំ

## របៀបចូលរួមវគ្គសិក្សា

*ម៉ាកដាឡា* ត្រូវបានបំបែកទៅជាពីរបីវគ្គវិញ ដើម្បីមានភាពងាយស្រួលក្នុងការសិក្សាពីដំណើរជីវិតរបស់នាងម៉ារា ដែលនាងបានធ្វើបន្ទាល់អំពីព្រះយេស៊ូវមានអំណាចឈ្នះលើអំនួតនៃភាពជាមនុស្ស។ វិធីដ៏ល្អបំផុតដើម្បីណែនាំអំពីការសិក្សាស្រាវជ្រាវដើម្បីធ្វើតាមមួយវគ្គម្ដងក្នុងមួយពេលតាមគំរូដែលបានផ្ដល់ឱ្យ។

វាគឺជាការចាំបាច់ក្នុងការធ្វើតាមគ្រប់ទាំងសំនួររៀងរាល់សប្ដាហ៍។ គន្លឹះគឺអនុញ្ញាតឱ្យក្រុមរបស់អ្នកពិភាក្សាដោយសេរី ពីអ្វីដែលវគ្គនីមួយៗបានបង្ហាញអំពីព្រះយេស៊ូវជានរណា និងការបំផ្លាស់បំប្រែរបស់នាងម៉ារា។ វាក៏ជាទំនួលខុសត្រូវរបស់អ្នកដែរ ក្នុងនាមជាអ្នកសម្របសម្រួល ដើម្បីបង្កើតបរិយាកាសដែលមានសុវត្ថិភាពសម្រាប់ក្រុមរបស់អ្នក។ ដើម្បីធ្វើការនេះបាន តួនាទីរបស់អ្នកគឺជួយផ្នែកខាងស្ដាប់ និងដឹកនាំ។ នេះគឺជាអ្វីដែលត្រូវធ្វើនៅក្នុង*ក្រុម* ពិភាក្សា និងមិនត្រូវធ្វើនៅពេលអធិប្បាយឡើយ។

ដើម្បីអាចចូលទៅកាន់វីដេអូខ្លីៗបាន ចូរទៅកាន់កម្មវិធីផលិតកម្មខ្សែភាពយន្តព្រះយេស៊ូវ ហើយចូលទៅកាន់របាស្វែងរក ដើម្បីស្វែងរករឿងភាគនីមួយៗ តាមរយៈអក្សរទ្រេតតូចៗខាងក្រោមវា ឬស្វែងរកវីដេអូនៅគេហទំព័រផលិតកម្មខ្សែភាពយន្តព្រះយេស៊ូវ ដោយចូលទៅកាន់ jesusfilm.org/watch។

## នេះគឺជាភាគនីមួយៗពីខ្សែភាពយន្ត *ម៉ាកដាឡា* ដែលប្រើសម្រាប់ការសិក្សានេះ៖

**មេរៀនទី១៖** ស្ត្រីគ្រប់គ្នានឹងឃើញ ហើយស្គាល់ (វគ្គ៖ *ម៉ារាម៉ាកដាឡា ចូលទៅកាន់ផ្ទះរបស់នាងរីវេដា*)។
**មេរៀនទី២៖** ព្រះយេស៊ូវ៖ លើសពីហោរា (វគ្គ៖ *ប្រកាសអំពីនាងម៉ារា*)។
**មេរៀនទី៣៖** រំដោះឱ្យរួចពីចំណង (វគ្គ៖ *ម៉ារាម៉ាកដាឡាមានសេរីភាពពីវិញ្ញាណអាក្រក់*)។
**មេរៀនទី៤៖** សេចក្ដីស្រឡាញ់ព្រះយេស៊ូវ (វគ្គ៖ *ព្រះយេស៊ូវប្រោសកូនប្រុសស្ត្រីមេម៉ាយឱ្យរស់ឡើងវិញ*)។
**មេរៀនទី៥៖** ជម្លោះ និងការបដិសេធ (វគ្គ៖ *ស្ត្រីនៅឯអណ្ដូង*)។
**មេរៀនទី៦៖** ការប្រោសឱ្យជា និងការស្ដារឡើងវិញ (វគ្គ៖ *ស្ត្រីធ្លាក់ឈាម*)។
**មេរៀនទី៧៖** ភាពអាម៉ាស់ និងកត្តិយស (វគ្គ៖ *ការអត់ទោសស្ត្រីកំផិតម្នាក់*)។
**មេរៀនទី៨៖** ការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ (វគ្គ៖ *ម៉ារាពន្យល់អំពីការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ*)។
**មេរៀនទី៩៖** ការស្គាល់ព្រះយេស៊ូវ និងការអត់ទោសរបស់ទ្រង់ (វគ្គ៖ *ជំនឿរបស់រីវេកា*)។
**មេរៀនទី១០៖** ការរស់នៅជាមួយព្រះយេស៊ូវ (វគ្គ៖ *រស់នៅក្នុងជីវិតគ្រីស្ទបរិស័ទ*)។

***យើងអធិស្ឋានសូមព្រះជាម្ចាស់ប្រទានពរអ្នក នៅពេលអ្នកទុកចិត្តលើព្រះអង្គ ក្នុងការប្រើអ្នកដើម្បីពន្យល់ពីនគររបស់ព្រះអង្គ។***

# មេរៀនទី១ ស្ត្រីម្នាក់ៗឃើញ និងស្គាល់

## ម៉ារាម៉ាកដាឡាទៅផ្ទះរបស់វីរកា (ទំនុកតម្កើង ១៣៩)

**ការមើលក្រោយ**

### ការថៃទាំ

- ចែកចាយពីរបៀបដែលអ្នកធ្វើ។
- អនុវត្តតាមដោយសប្បុរស

### ថ្វាយបង្គំព្រះ

- ថ្វាយបង្គំព្រះជាមួយគ្នាដោយចម្រៀង និងអធិស្ឋាន។

### សាទរភាពស្មោះត្រង់

- លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងភាពជ័យជម្នះ។

### ចាប់យកនិមិត្ត

- លើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីឱ្យមានការប្ដូរផ្ដាច់ដើរតាមព្រះយេស៊ូវ។

**ការមើលទៅលើ**

ប្រើ QR កូដនេះ ដើម្បីមើលផ្នែកនៃកម្មវិធីនេះជាភាសារបស់អ្នកលើឧបករណ៍ឆ្លាតវៃរបស់អ្នក។

នៅក្នុងទីរហោស្ថាន រង្វេង ឯកា និងធ្លាក់ទឹកចិត្ត ព្រះជាម្ចាស់ជួបជាមួយស្ត្រីបម្រើម្នាក់ឈ្មោះហាការ។ ព្រះគម្ពីរចែងថា៖ «នោះនាងក៏ហៅព្រះនាមព្រះយេហូវ៉ា ដែលកំពុងមានបន្ទូលនឹងនាងថា «ព្រះដ៏ទតឃើញ» ដ្បិតនាងគិតថា នៅទីនេះអញបានឃើញព្រះដែលទ្រង់ទតឃើញអញទេតើ...» (លោកុប្បត្តិ ១៦:១៣-១៤ ពគប) ថ្ងៃនេះ យើងចាប់ផ្ដើមដំណើររបស់យើងជាមួយគ្នា រៀនអំពីព្រះជាម្ចាស់ដែលពិតជាទតឃើញ ហើយស្គាល់យើងម្នាក់ៗ។

**ជំហានទី១៖ បង្ហាញ។** ចូរទស្សនាមួយវគ្គពីរដង។
**ជំហានទី២៖ ប្រាប់។** ចូរសួរសមាជិកក្រុមឱ្យនិទានវគ្គនៃសាច់រឿងចេញពីពាក្យរបស់គេផ្ទាល់។
**ជំហានទី៣៖ បញ្ជប់។** អនុញ្ញាតឱ្យក្រុមបំពេញចន្លោះនៅក្នុងសាច់រឿងដែលមិនបាននិទាន ឬអាចនិយាយកែតម្រង់ណាមួយ។
**ជំហានទី៤៖ ចូរពិភាក្សា។** ក្រុមពិភាក្សា។ ចំណាំ៖ មិនចាំបាច់ត្រូវពិភាក្សាគ្រប់សំនួរទាំងអស់នោះទេ។

*១. តើអ្នកចូលចិត្តអ្វីជាងគេនៅក្នុងសាច់រឿង? តើអ្វីទៅដែលធ្វើឱ្យអ្នកចាប់អារម្មណ៍?*
*២. ហេតុអ្វីបានជាអ្នកគិតថា វីរកាសង្ស័យថាព្រះអាចស្រឡាញ់នាង ឬស្គាល់នាង?*
*៣. មានមនុស្សជាច្រើនសព្វថ្ងៃនេះ ដែលនិយាយអំពីព្រះជាម្ចាស់។ តើយើងអាចដឹងថាព្រះអង្គពិតជាគិតគូ ឬយកព្រះទ័យទុកដាក់នឹងយើង?*
*៤. សូមអានទំនុកតម្កើង ១៣៩:១-១៨ តើហោរាដាវីឌមានប្រសាសន៍នៅក្នុងរាជសារនេះ អំពីការដែលព្រះស្គាល់យើងច្បាស់យ៉ាងណា?*

**ចូរសិក្សាឱ្យកាន់តែស៊ីជម្រៅជាងនេះ (ចូរពិភាក្សាបន្ថែម ប្រសិនបើមានពេល...)**

*៥. តើវាបានធ្វើឱ្យអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច ដែលព្រះបានទតឃើញ និងយល់គ្រប់យ៉ាងអំពីអ្នក?*
*៦. ស្ដេចដាវីឌបានសរសេរថា ព្រះទ្រង់ជ្រាបគ្រប់យ៉ាងអំពីយើង លើសពីនោះ ព្រះអង្គស្មោះត្រង់នឹងស្រឡាញ់ និងដឹកនាំយើង ព្រមទាំងគង់នៅជាមួយយើងជានិច្ច។ ហេតុអ្វីបានជាអ្នកគិតថាពេលខ្លះយើងបរាជ័យក្នុងការជឿលើការនេះ?*

## សេចក្តីបញ្ចប់

ចូរពិចារណាថាតើព្រះដែលបង្កបង្កើតរបស់អ្នក អាចស្គាល់ និងស្រឡាញ់ទាំងស្រុងមានន័យដូចម្ដេច។ ប្រសិនបើ ព្រះជាម្ចាស់ទតឃើញគ្រប់ទាំងផ្នែករបស់អ្នកហើយ បានគ្របបាំង និងបានឱ្យតម្លៃ? ព្រះយេស៊ូវបានប្រទានការអត់ទោសសម្រាប់ភាពខ្វះចន្លោះរបស់អ្នក និងគោលបំណងសម្រាប់គ្រប់យ៉ាងនៅក្នុងជីវិតរបស់អ្នក។ ព្រះអង្គសន្យាអំពីជីវិតអស់កល្បជានិច្ច ហើយព្រះវត្តនាមរបស់ទ្រង់គង់នៅជាមួយមនុស្សទាំងអស់ដែលចូលមកឯទ្រង់។ ព្រះអង្គបានបង្កើតអ្នកមក ឱ្យមានលក្ខណៈដូចជាព្រះជាម្ចាស់ ហើយបន្ទាប់មក ឱ្យរូបរាងដូចជាព្រះអង្គ។ អ្នកមានភាពថ្លៃថ្នូរ និងមានតម្លៃ ដោយសារព្រះអង្គបានបង្កើតអ្នកមក ឱ្យមានលក្ខណៈដូចជាព្រះជាម្ចាស់ (លោកុប្បត្តិ ១:២៦-២៧)។ ពិចារណាអំពីព្រះយេស៊ូវ។

**ការមើលទៅមុខ**

### ការប្រព្រឹត្តតាម

- តើព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ ថាអាចទុកចិត្តបានយ៉ាងដូចម្ដេច?
- តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនអំពីព្រះជាម្ចាស់យ៉ាងដូចម្ដេច?

### ការអនុត្ត

- ការអនុវត្តអំពីការនិទានសាច់រឿងដល់គ្នាទៅវិញទៅមក។

### ការចែកចាយ

- តើអ្នកណាដែលអ្នកនឹងចែកចាយរឿងនេះជាមួយ?

### អធិស្ឋាន

- អរគុណព្រះសម្រាប់អ្វីដែលបានរៀន។
- អធិស្ឋានដល់គ្នាទៅវិញទៅមក។
- អធិស្ឋានសម្រាប់អ្នកដទៃនៅក្នុងសហគមន៍។

# មេរៀនទី២ ព្រះយេស៊ូវគឺខ្ពស់លើសពីហោរា

## ប្រកាសអំពីនាងម៉ារា (លូកា ១:២៦-៣៧)

**ការមើលក្រោយ**

### ការថែទាំ
- ចែកចាយពីរបៀបដែលអ្នកធ្វើ។
- អនុវត្តតាមដោយសប្បុរស។

### ថ្វាយបង្គំព្រះ
- ថ្វាយបង្គំព្រះជាមួយគ្នាដោយចម្រៀង និងអធិស្ឋាន។

### សាទរភាពស្មោះត្រង់
- លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងភាពជ័យជម្នះ។

### ចាប់យកនិមិត្ត
- លើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីឱ្យមានការប្តេជ្ញាចិត្តដើរតាមព្រះយេស៊ូវ។

---

**ការមើលទៅលើ**

បីបួនរយឆ្នាំមុនព្រះយេស៊ូវ ហោរាអេសាយបានទាយថា នឹងមានទីសម្គាល់មួយដល់អ៊ីស្រាអែល៖ នាងព្រហ្មចារី នឹងមានគភ៌ ប្រសូតបានបុត្រាមួយ (អេសាយ ៧:១៤)។ បុត្រានោះគឺព្រះយេស៊ូវ៖ ទ្រង់បន្ទាបអង្គទ្រង់ទាបបំផុត ព្រះអង្គបន្ទាបអង្គទ្រង់ទាបអស់ទាំងអ្វីៗដែលមានជីវិត៖ ជាបុត្រតូច។ ព្រះអង្គមានបទពិសោធជាមនុស្សពេលលេញ បង្ហាញថា ព្រះអង្គគឺជាព្រះ និងជាមនុស្សពេញលក្ខណៈផងដែរ។ ព្រះអង្គព្រមប្រឈមនឹងការឈឺចាប់ ជំងឺ ភាពអត់ឃ្លាន និងស្រេក សោកស្តាយ និងរងរបួស ដើម្បីស្តារទំនាក់ទំនងជាមួយយើង។ ហើយនៅពេលព្រះយេស៊ូវប្រសូតមក ព្រះអង្គប្រសូតនឹងនាងក្រមុំព្រហ្មចារី៖ គឺនាងម៉ារា។

**ជំហានទី១៖ បង្ហាញ។** ចូរទស្សនាមួយវគ្គពីរដង។
**ជំហានទី២៖ ប្រាប់។** ចូរសួរសមាជិកក្រុមឱ្យនិទានវគ្គនៃសាច់រឿងចេញពីពាក្យរបស់គេផ្ទាល់។
**ជំហានទី៣៖ បញ្ជាប់។** អនុញ្ញាតឱ្យក្រុមបំពេញចន្លោះនៅក្នុងសាច់រឿងដែលមិនបាននិទាន ឬអាចនិយាយកែតម្រង់ណាមួយ។
**ជំហានទី៤៖ ចូរពិភាក្សា។** ចូរពិភាក្សាសំណួរផ្សេងៗ៖

ប្រើ QR កូដនេះ ដើម្បីមើលផ្នែកនៃកម្មវិធីនេះជាភាសារបស់អ្នកលើឧបករណ៍ឆ្លាតវៃរបស់អ្នក។

*១. តើអ្នកចូលចិត្តអ្វីជាងគេនៅក្នុងសាច់រឿង? តើអ្វីទៅដែលធ្វើឱ្យអ្នកចាប់អារម្មណ៍?*
*២. តើអ្នកគិតថា នាងម៉ារាមានអារម្មណ៍យ៉ាងណា នៅពេលនាងបានឮរាជសាររបស់ទេវតា? តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច ប្រសិនបើ អ្នកបានទទួលដំណឹងបែបនេះ?*
*៣. ទេវតាបាននិយាយថា «គ្មានអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតនោះទេ» តើអារម្មណ៍មួយណាដែលអ្នកគិតថា មិនអាចទៅរួច នៅពេលនេះ?*
*៤. តើមានន័យដូចម្តេច ដែលទេវតានិយាយថា គេហៅបុត្រតូចនោះថា «បុត្ររបស់ព្រះជាម្ចាស់?»។*

**ចូរសិក្សាឱ្យកាន់តែស៊ីជម្រៅជាងនេះ (ចូរពិភាក្សាបន្ថែម ប្រសិនបើមានពេល...)**
*៥. ហេតុអ្វីបានជាអ្នកគិតថា ព្រះយេស៊ូវប្រសូតនឹងនាងព្រហ្មចារីថាមិនសំខាន់?*

### សេចក្តីបញ្ចប់
ចូរពិចារណាអំពីលក្ខណៈនៃការចាប់កំណើត និងប្រសូតដ៏អស្ចារ្យរបស់ព្រះយេស៊ូវ។ ព្រះអង្គ ទាំងពីរ ជាមនុស្ស និងជាព្រះ។ ព្រះអង្គក៏ជាព្រះដែលបង្កបង្កើតពិភពលោកដែរ។ ព្រះអង្គគឺជាបុគ្គលដែលយើងអាចជាប់ទាកទងជាមួយបាន ហើយអាចទុកចិត្តបានថាជាព្រះអង្គសង្គ្រោះ។ ពិចារណាអំពីព្រះយេស៊ូវ។

---

**ការមើលទៅមុខ**

### ការប្រព្រឹត្តតាម
- តើព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ ថាអាចទុកចិត្តបានយ៉ាងដូចម្តេច?
- តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនអំពីព្រះជាម្ចាស់យ៉ាងដូចម្តេច?

### ការអនុត្ត
- ការអនុវត្តអំពីការនិទានសាច់រឿងដល់គ្នាទៅវិញទៅមក។

### ការចែកចាយ
- តើអ្នកណាដែលអ្នកនឹងចែកចាយរឿងនេះជាមួយ?

### អធិស្ឋាន
- អរគុណព្រះសម្រាប់អ្វីដែលបានរៀន។
- អធិស្ឋានដល់គ្នាទៅវិញទៅមក។
- អធិស្ឋានសម្រាប់អ្នកដទៃនៅក្នុងសហគមន៍។

# មេរៀនទី៣ រំដោះឱ្យរួចពីចំណង

## ម៉ារាម៉ាកដាឡា មានសេរីភាពពីវិញ្ញាណអាក្រក់ (លូកា ៨:១-២)

**ការមើលក្រោយ**

### ការថែទាំ
- ចែកចាយពីរបៀបដែលអ្នកធ្វើ។
- អនុវត្តតាមដោយសប្បុរស។

### ថ្វាយបង្គំព្រះ
- ថ្វាយបង្គំព្រះជាមួយគ្នាដោយចម្រៀង និងអធិស្ឋាន។

### សាទរភាពស្មោះត្រង់
- លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងភាពជ័យជម្នះ។

### ចាប់យកនិមិត្ត
- លើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីឱ្យមានការប្តូរផ្តាច់ដើរតាមព្រះយេស៊ូវ។

---

**ការមើលទៅលើ**

ការជួញដូរមនុស្ស ការញៀន ការរត់គេពីបញ្ហាជាដើម។ មានភាពជាទាសករជាច្រើនប្រភេទនៅក្នុងពិភពលោកសព្វថ្ងៃនេះ។ ព្រះគម្ពីរបង្រៀនយើងថា មនុស្សគឺជាប់ជាឈ្លើយនៃអំពើបាប ប៉ុន្តែក៏បង្រៀនយើងថា យើងអាចរកឃើញសេរីភាពបានផងដែរ។ នៅក្នុងរឿងនេះ សូមមើលនាងម៉ារា ត្រូវបានជាប់ជាឈ្លើយ និងមានអារក្សចូល ហើយក៏បានជួបជាមួយសិទ្ធិអំណាច និងព្រះចេស្តារបស់ព្រះយេស៊ូវ។

**ជំហានទី១៖ បង្ហាញ។** ចូរទស្សនាមួយវគ្គពីរដង។
**ជំហានទី២៖ ប្រាប់។** ចូរសួរសមាជិកក្រុមឱ្យនិទានវគ្គនៃសាច់រឿងចេញពីពាក្យរបស់គេផ្ទាល់។
**ជំហានទី៣៖ បញ្ចប់។** អនុញ្ញាតឱ្យក្រុមបំពេញចន្លោះនៅក្នុងសាច់រឿងដែលមិនបាននិទាន ឬអាចនិយាយកែតម្រង់ណាមួយ។
**ជំហានទី៤៖ ចូរពិភាក្សា។** ចូរពិភាក្សាសំណួរផ្សេងៗ៖

*១. តើអ្នកចូលចិត្តអ្វីជាងគេនៅក្នុងសាច់រឿង? តើអ្វីទៅដែលធ្វើឱ្យអ្នកចាប់អារម្មណ៍?*
*២. តើភាពជាទាសកររបស់នាងម៉ារាប៉ះពាល់លក្ខណៈសម្បត្តិរបស់នាង និងនៅក្នុងសហគមន៍របស់នាងយ៉ាងដូចម្តេចខ្លះ?*
*៣. តើព្រះយេស៊ូវបានឆ្លើយតបចំពោះនាងម៉ារា បើកសម្តែងអំពីទ្រង់យ៉ាងដូចម្តេចខ្លះ?*
*៤. តើនាងម៉ារាបានផ្លាស់ប្រែយ៉ាងដូចម្តេចខ្លះ បន្ទាប់ពីព្រះយេស៊ូវរំដោះនាងឱ្យបានរួច?*

**ចូរសិក្សាឱ្យកាន់តែស៊ីជម្រៅជាងនេះ (ចូរពិភាក្សាបន្ថែម ប្រសិនបើមានពេល...)**
*៥. ហេតុអ្វីបានជាសំខាន់ ដែលវិញ្ញាណអាក្រក់ដឹងថាព្រះយេស៊ូវជានរណា ហៅព្រះថា «ជាព្រះដ៏បរិសុទ្ធ?»*
*៦. តើអ្នកគិតដូចម្តេចដែរ អំពីគំនិតបណ្តាជនគិតអំពីព្រះយេស៊ូវ បន្ទាប់ពីមើលឃើញទ្រង់រំដោះនាងម៉ារាឱ្យមានសេរីភាព?*
*៧. សូមស្រមៃមើលថាអ្នកជានាងម៉ារានៅក្នុងសាច់រឿង។ តើអ្នកគិតថា អ្នកអាចមានអារម្មណ៍យ៉ាងដូចម្តេចចំពោះព្រះយេស៊ូវ?*

ប្រើ QR កូដនេះ ដើម្បីមើលផ្នែកនៃកម្មវិធីនេះជាភាសារបស់អ្នកលើឧបករណ៍ឆ្លាតវៃរបស់អ្នក។

## សេចក្តីបញ្ចប់

ចូរពិចារណាអំពីសេរីភាពដែលនាងម៉ារាមានបទពិសោធនៅក្នុងរឿងនេះ។ នឹកចាំអំពីភាពដឹងច្បាស់នៅក្នុងភ្នែកនាងម៉ារា បន្ទាប់ពីទទួលបានសេរីភាពហើយ។ តើអ្នកអាចជឿទេថា នេះគឺជាស្ត្រីដដែលតាំងពីដំបូងនៃវគ្គនេះ? សូមស្រមៃមើលថា ព្រះយេស៊ូវបានរំដោះអ្នកឱ្យមានសេរីភាពពីចំណងផ្សេងៗ និងពីភាពជាទាសករ។ តើអ្នកគិតឱ្យព្រះអង្គបង្កើតជាអ្នកថ្មីយ៉ាងដូចម្តេច? ចូរអនុញ្ញាតឱ្យព្រះដកយកបន្ទុកដែលអ្នកបានលីនៅលើស្មាររបស់អ្នក ហើយដាក់លើទ្រង់វិញ។ ពិចារណាអំពីព្រះយេស៊ូវ។

---

**ការមើលទៅមុខ**

### ការប្រព្រឹត្តតាម
- តើព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ ថាអាចទុកចិត្តបានយ៉ាងដូចម្តេច?
- តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនអំពីព្រះជាម្ចាស់យ៉ាងដូចម្តេច?

### ការអនុត្ត
- ការអនុវត្តអំពីការនិទានសាច់រឿងដល់គ្នាទៅវិញទៅមក។

### ការចែកចាយ
- តើអ្នកណាដែលអ្នកនឹងចែកចាយរឿងនេះជាមួយ?

### អធិស្ឋាន
- អរគុណព្រះសម្រាប់អ្វីដែលបានរៀន។
- អធិស្ឋានដល់គ្នាទៅវិញទៅមក។
- អធិស្ឋានសម្រាប់អ្នកដទៃនៅក្នុងសហគមន៍។

# មេរៀនទី៤ សេចក្ដីស្រឡាញ់របស់ព្រះយេស៊ូវ
## ព្រះយេស៊ូវប្រោសកូនប្រុសស្ត្រីមេម៉ាយឱ្យរស់ឡើងវិញ (លូកា ៧:១១-១៧)

**ការមើលក្រោយ**

### ការថែទាំ
- ចែកចាយពីរបៀបដែលអ្នកធ្វើ។
- អនុវត្តតាមដោយសប្បុរស។

### ថ្វាយបង្គំព្រះ
- ថ្វាយបង្គំព្រះជាមួយគ្នាដោយចម្រៀង និងអធិស្ឋាន។

### សាទរភាពស្មោះត្រង់
- លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងភាពជ័យជម្នះ។

### ចាប់យកនិមិត្ត
- លើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីឱ្យមានការប្តេជ្ញាចិត្តដើរតាមព្រះយេស៊ូវ។

---

**ការមើលទៅលើ**

ប្រើ QR កូដនេះ ដើម្បីមើលផ្នែកនៃកម្មវិធីនេះជាភាសារបស់អ្នកលើឧបករណ៍ឆ្លាតវៃរបស់អ្នក។

សេចក្តីសោកសៅគឺបញ្ហាក់ថាកើតទុក្ខជាខ្លាំង ជាពិសេសកើតឡើងដោយសារនរណាម្នាក់ស្លាប់។ នៅក្នុងសាច់រឿងនេះ ស្ត្រីមេម៉ាយកំពុងកើតទុក្ខខ្លាំងដោយសារកូនប្រុសតែមួយរបស់នាងបានស្លាប់។ នាងម៉ាពបានឃើញព្រះយេស៊ូវយាងចូលមកជិតស្ត្រីនោះ ហើយបានបំពេញសេចក្តីត្រូវការនៃដួងចិត្តរបស់នាង។ នៅក្នុងឧទាហរណ៍នេះ ព្រះយេស៊ូវជ្រើសរើសក្នុងការព្យាបាលកូនប្រុសតែមួយរបស់នាងឱ្យជា បានប្រទានអំណោយដ៏មានតម្លៃបំផុតត្រឡប់ទៅនាងវិញ។ ព្រះអង្គអាចនឹងមិនធ្វើដូច្នេះក្នុងគ្រប់កាលៈទេសៈទេ សូម្បីតែស្ថិតក្នុងភាពសោកសៅដ៏ឈឺចាប់បំផុតក្តី។

**ជំហានទី១៖ បង្ហាញ។** ចូរទស្សនាមួយវគ្គពីរដង។
**ជំហានទី២៖ ប្រាប់។** ចូរសួរសមាជិកក្រុមឱ្យនិទានវគ្គនៃសាច់រឿងចេញពីពាក្យរបស់គេផ្ទាល់។
**ជំហានទី៣៖ បញ្ជប់។** អនុញ្ញាតឱ្យក្រុមបំពេញចន្លោះនៅក្នុងសាច់រឿងដែលមិនបាននិទាន ឬអាចនិយាយកែតម្រង់ណាមួយ។
**ជំហានទី៤៖ ចូរពិភាក្សា។** ចូរពិភាក្សាសំណួរផ្សេងៗ៖

*១. តើអ្នកចូលចិត្តអ្វីជាងគេនៅក្នុងសាច់រឿង? តើអ្វីទៅដែលធ្វើឱ្យអ្នកចាប់អារម្មណ៍?*
*២. ព្រះយេស៊ូវបានបញ្ជាប់អ្វីដែលព្រះអង្គកំពុងមានបន្ទូលនឹងស្ត្រីនោះ តើការនេះ បង្ហាញពីអ្វីនៅក្នុងព្រះហឫទ័យរបស់ទ្រង់?*
*៣. តើវាបាននិយាយអ្វីអំពីព្រះយេស៊ូវ ដែលព្រះអង្គអាចប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ?*
*៤. តើអ្នកធ្លាប់ស្ថិតក្នុងស្ថានភាពដែលមានអារម្មណ៍ថាអស់សង្ឃឹមទេ?*

**ចូរសិក្សាឱ្យកាន់តែស៊ីជម្រៅជាងនេះ (ចូរពិភាក្សាបន្ថែម ប្រសិនបើមានពេល...)**
*៥. តើបណ្តាជនឆ្លើយតបយ៉ាងដូចម្តេច នៅពេលព្រះយេស៊ូវប្រោសក្មេងប្រុសឱ្យរស់ពីស្លាប់ឡើងវិញ? តើស្ត្រីមេម៉ាយនោះឆ្លើយតបយ៉ាងដូចម្តេច?*
*៦. តើមានអ្វី ឬនរណាម្នាក់ដែលអ្នកមានការសោកសៅនៅពេលនេះ? បើមាន តើអ្នកនឹងទុកចិត្តដល់ព្រះដើម្បីឱ្យអ្នកក្នុងទុក្ខសោកនេះបានទេ?*

### សេចក្តីបញ្ចប់
មានតែព្រះជាម្ចាស់ទេដែលប្រទានដង្ហើយដល់មនុស្សស្លាប់បាន។ ចូរពិចារណាអំពីសេចក្តីពិតដែលព្រះយេស៊ូវគឺជាព្រះ។ ព្រះអង្គអាចនឹងប្រោសមនុស្សដែលស្លាប់ឱ្យមានជីវិតឡើងវិញ មិនសម្រាប់តែបុរសម្នាក់នេះប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គស្រឡាញ់ និងពេញដោយភាពទន់ភ្លន់ និងកក់ក្តៅ។ ពិចារណាអំពីព្រះយេស៊ូវ។

---

**ការមើលទៅមុខ**

### ការប្រព្រឹត្តតាម
- តើព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ ថាអាចទុកចិត្តបានយ៉ាងដូចម្តេច?
- តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនអំពីព្រះជាម្ចាស់យ៉ាងដូចម្តេច?

### ការអនុវត្ត
- ការអនុវត្តអំពីការនិទានសាច់រឿងដល់គ្នាទៅវិញទៅមក។

### ការចែកចាយ
- តើអ្នកណាដែលអ្នកនឹងចែកចាយរឿងនេះជាមួយ?

### អធិស្ឋាន
- អរគុណព្រះសម្រាប់អ្វីដែលបានរៀន។
- អធិស្ឋានដល់គ្នាទៅវិញទៅមក។
- អធិស្ឋានសម្រាប់អ្នកដទៃនៅក្នុងសហគមន៍។

# មេរៀនទី៥ ជម្លោះ និងការបដិសេធ

## ស្ត្រីនៅឯអណ្តូង (យ៉ូហាន ៤:១-៤២)

**ការមើលក្រោយ**

### ការថៃទាំ
- ចែកចាយពីរបៀបដែលអ្នកធ្វើ។
- អនុវត្តតាមដោយសប្បុរស។

### ថ្វាយបង្គំព្រះ
- ថ្វាយបង្គំព្រះជាមួយគ្នាដោយចម្រៀង និងអធិស្ឋាន។

### សាទរភាពស្មោះត្រង់
- លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងភាពជ័យជម្នះ។

### ចាប់យកនិមិត្ត
- លើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីឱ្យមានការប្តេជ្ញាចិត្តដើរតាមព្រះយេស៊ូវ។

---

**ការមើលទៅលើ**

តើអ្នកធ្លាប់ត្រូវបានគេថ្កោលទោស ឬមើលងាយដោយសារនរណាម្នាក់ទេ? នៅក្នុងរឿងនេះ នាងម៉ារាមើលឃើញអំពីការជាប់គាំងរបស់ស្ត្រីសាសន៍សាម៉ារី ដែលនាងត្រូវធ្វើដំណើររាល់ថ្ងៃទៅកាន់អណ្តូងទឹក។ សង្ឃឹមថានឹងមិនបានជួបនរណាម្នាក់ឡើយ ស្ត្រីនេះដើរម្នាក់ឯង នៅក្រោមកម្តៅថ្ងៃ។ នៅពេលនាងមកដល់ នាងខកចិត្តនៅពេលបានឃើញបុរសម្នាក់។ នាងបានដឹងថា បុរសនោះមិនគ្រាន់តែជាបុរសធម្មតានោះទេ ប៉ុន្តែគាត់គឺជាសាសន៍យូដា។ សាសន៍សាម៉ារីគឺជាសាសន៍កូនកាត់ជាមួយសាសន៍យូដា និងមិនមែនសាសន៍យូដា គឺជាអ្នកដែលបញ្ចូលគំនិតសាសនា និងជំនឿជាមួយគ្នា។ សាសន៍យូដា និងសាសន៍សាម៉ារីស្អប់គ្នាទៅវិញទៅមក ប៉ុន្តែមនុស្សពីរក្រុមនេះ ទន្ទឹងរង់ចាំការយាងមករបស់ព្រះមេស្ស៊ី ឬព្រះអង្គសង្គ្រោះ ដែលនឹងនាំមកនូវការអត់ទោសបាបរបស់ពួកគេ។ សូមស្រមៃមើលស្ត្រីម្នាក់នេះភ្ញាក់ផ្អើលនៅពេលបុរសម្នាក់នេះ ព្រះយេស៊ូវ មិនខ្វល់ពីការបង្គាប់បញ្ជាប្បេធម៌ ហើយបានឈោងចាប់ដល់នាង។ នៅចុងបញ្ចប់នៃសាច់រឿង ស្ត្រីសាសន៍សាម៉ារាដែលជាប់គាំម្នាក់នេះ បានក្លាយជាមនុស្សដំបូងដែលព្រះយេស៊ូវបានបង្ហាញអង្គទ្រង់យ៉ាងច្បាស់ថា ជាព្រះមេស្ស៊ី។

ប្រើ QR កូដនេះ ដើម្បីមើលផ្នែកនៃកម្មវិធីនេះជាភាសារបស់អ្នកលើឧបករណ៍ឆ្លាតវៃរបស់អ្នក។

**ជំហានទី១៖ បង្ហាញ។** ចូរទស្សនាមួយវគ្គពីរដង។
**ជំហានទី២៖ ប្រាប់។** ចូរសួរសមាជិកក្រុមឱ្យនិទានវគ្គនៃសាច់រឿងចេញពីពាក្យរបស់គេផ្ទាល់។
**ជំហានទី៣៖ បញ្ចប់។** អនុញ្ញាតឱ្យក្រុមបំពេញចន្លោះនៅក្នុងសាច់រឿងដែលមិនបាននិទាន ឬអាចនិយាយកែតម្រង់ណាមួយ។
**ជំហានទី៤៖ ចូរពិភាក្សា។** ចូរពិភាក្សាសំណួរផ្សេងៗ៖

*១. តើអ្នកចូលចិត្តអ្វីជាងគេនៅក្នុងសាច់រឿង? តើអ្វីទៅដែលធ្វើឱ្យអ្នកចាប់អារម្មណ៍?*
*២. ហេតុអ្វីបានជាសំខាន់ ដែលព្រះយេស៊ូវជ្រាបពីប្រោសកាលរបស់ស្ត្រីនេះគ្រប់យ៉ាង?*
*៣. តើអ្នកគិតយ៉ាងដូចម្តេច អំពីអារម្មណ៍របស់ស្ត្រីនោះ នៅពេលព្រះយេស៊ូវប្រាប់នាងអំពីជីវិតរបស់នាងផ្ទាល់ និងបាបពីអតីតកាលរបស់នាង?*
*៤. នៅពេលពួកសិស្សឃើញព្រះយេស៊ូវកំពុងមានបន្ទូលទៅកាន់ស្ត្រីសាសន៍សាម៉ារី តើការឆ្លើយតបពួកគេបង្ហាញពីការបដិសេធរបស់ពួកគេយ៉ាងដូចម្តេច? តើការនេះនិយាយយ៉ាងណាអំពីព្រះយេស៊ូវ?*

**ចូរសិក្សាឱ្យកាន់តែស៊ីជម្រៅជាងនេះ (ចូរពិភាក្សាបន្ថែម ប្រសិនបើមានពេល...)**
*៥. តើអ្នកគិតថា ព្រះយេស៊ូវកំពុងព្យាយាមបង្រៀនអ្នកដើរតាមព្រះយ៉ាងណានៅក្នុងសាច់រឿងនេះយ៉ាងណា?*
*៦. តើស្ត្រីនោះបានធ្វើអ្វី នៅពេលព្រះយេស៊ូវប្រាប់នាងថា ទ្រង់គឺជាព្រះមេស្ស៊ី ដែលបានសន្យានោះ?*

## សេចក្តីបញ្ចប់
ចូរពិចារណា តើវាមានន័យដូចម្តេចដែលថា ព្រះយេស៊ូវជ្រាបពីអតីតកាល៖ គ្រប់ទាំងការសម្រេចចិត្តដែលមិនល្អ គ្រប់ទាំងការរៀនខុស និងគ្រប់ភាពអាម៉ាស់របស់អ្នក។ នៅពេលនេះ ចូរពិចារណាអំពីសេចក្តីពិតដែលសូម្បីតែអ្វីៗទាំងអស់ត្រូវបានបង្ហាញព្រះអង្គនៅតែមើលមកអ្នកដោយការគោរព និងមានសេចក្តីថ្លៃថ្នូរ។ ហើយមិនគ្រាន់តែអ្នកទេ ប៉ុន្តែមនុស្សដែលអ្នកស្អប់ដែរ។ ចូរពិចារណាចំពោះបំណងប្រាថ្នារបស់ទ្រង់សម្រាប់មនុស្សទាំងអស់ដើម្បីឱ្យបានស្គាល់ទ្រង់។ ពិចារណាអំពីព្រះយេស៊ូវ។

---

**ការមើលទៅមុខ**

### ការប្រព្រឹត្តតាម
- តើព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ ថាអាចទុកចិត្តបានយ៉ាងដូចម្តេច?
- តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនអំពីព្រះជាម្ចាស់យ៉ាងដូចម្តេច?

### ការអនុត្ត
- ការអនុវត្តអំពីការនិទានសាច់រឿងដល់គ្នាទៅវិញទៅមក។

### ការចែកចាយ
- តើអ្នកណាដែលអ្នកនឹងចែកចាយរឿងនេះជាមួយ?

### អធិស្ឋាន
- អរគុណព្រះសម្រាប់អ្វីដែលបានរៀន។
- អធិស្ឋានដល់គ្នាទៅវិញទៅមក។
- អធិស្ឋានសម្រាប់អ្នកដទៃនៅក្នុងសហគមន៍។

# មេរៀនទី៦ ការប្រោសឱ្យជា និងការស្ដារឡើងវិញ

## ស្ត្រីធ្លាក់ឈាម (យ៉ូហាន ៨:៤០-៤៨)

**ការមើលក្រោយ**

### ការថែទាំ

- ចែកចាយពីរបៀបដែលអ្នកធ្វើ។
- អនុវត្តតាមដោយសប្បុរស។

### ថ្វាយបង្គំព្រះ

- ថ្វាយបង្គំព្រះជាមួយគ្នាដោយចម្រៀង និងអធិស្ឋាន។

### សាទរភាពស្មោះត្រង់

- លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងភាពជ័យជម្នះ។

### ចាប់យកនិមិត្ត

- លើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីឱ្យមានការប្ដូរផ្ដាច់ដើរតាមព្រះយេស៊ូវ។

**ការមើលទៅលើ**

ប្រើ QR កូដនេះ ដើម្បីមើលផ្នែកនៃកម្មវិធីនេះជាភាសារបស់អ្នកលើឧបករណ៍ឆ្លាតវៃរបស់អ្នក។

តើអ្នកធ្លាប់មានអារម្មណ៍ថានៅឆ្ងាយពីគេ ឃ្លាតឆ្ងាយខាងរូបកាយ របួសផ្លូវអារម្មណ៍ ដែលអ្នកខំព្យាយាមជួសជុលវាឬទេ? សង្ឃឹមថានឹងមានគេកត់សម្គាល់ ស្ត្រីនៅក្នុងសាច់រឿងនេះ បានជឿថា ប្រសិនបើនាងគ្រាន់តែប៉ះជាអាវផាយរបស់ព្រះយេស៊ូវ នាងនឹងបានជាពីស្ថានភាពនៃការធ្លាក់ឈាមរបស់នាង ដែលកាន់តែអាក្រក់ទៅៗទោះបីជាខំព្យាបាលអស់រយៈពេលជាច្រើនឆ្នាំហើយក្ដី។ ស្ថានភាពនៃការធ្លាក់ឈាម បានធ្វើឱ្យនាងជាមនុស្សដែលគេបោះបង់ចោល និងមានឈ្មោះថាជាស្ត្រីដែលមិនស្អាត ស្របតាមក្រឹត្យវិន័យរបស់សាសនានៅពេលនោះ។ នៅចំកណ្ដាលនៃបណ្ដាជន នាងបានសម្រេចចិត្តក្នុងការព្យាយាមចូលទៅប៉ះព្រះយេស៊ូវ ខណៈដែលនាងម៉ារា និងអ្នកផ្សេងទៀតនៅឈរក្បែរនោះ។ សូមទស្សនានូវអ្វីដែលបានកើតឡើង។

**ជំហានទី១៖ បង្ហាញ។** ចូរទស្សនាមួយវគ្គពីរដង។
**ជំហានទី២៖ ប្រាប់។** ចូរសួរសមាជិកក្រុមឱ្យនិទានវគ្គនៃសាច់រឿងចេញពីពាក្យរបស់គេផ្ទាល់។
**ជំហានទី៣៖ បញ្ចប់។** អនុញ្ញាតឱ្យក្រុមបំពេញចន្លោះនៅក្នុងសាច់រឿងដែលមិនបាននិទាន ឬអាចនិយាយកែតម្រង់ណាមួយ។
**ជំហានទី៤៖ ចូរពិភាក្សា។** ចូរពិភាក្សាសំណួរផ្សេងៗ៖

*១. តើអ្នកចូលចិត្តអ្វីជាងគេនៅក្នុងសាច់រឿង? តើអ្វីទៅដែលធ្វើឱ្យអ្នកចាប់អារម្មណ៍?*
*២. ហេតុអ្វីបានជាអ្នកគិតថា ព្រះយេស៊ូវបានបង្ហាញអត្តសញ្ញាណរបស់នាងនៅចំពោះហ្វូងមនុស្ស?*
*៣. ហេតុអ្វីបានជាការឆ្លើយរបស់ព្រះយេស៊ូវចំពោះការប្រកាសរបស់នាងសំខាន់?*
*៤. សូមស្រមៃថាអ្នកជាស្ត្រីនៅក្នុងសាច់រឿង។ តើអ្នកមានអារម្មណ៍បែបណាបន្ទាប់ពីអ្នកមានអារម្មណ៍ថាបានជាលើកដំបូង ហើយតើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចចំពោះព្រះយេស៊ូវ?*

**ចូរសិក្សាឱ្យកាន់តែស៊ីជម្រៅជាងនេះ (ចូរពិភាក្សាបន្ថែម ប្រសិនបើមានពេល...)**
*៥. តើមានន័យយ៉ាងដូចម្ដេចដែលព្រះយេស៊ូវអាចធ្វើអ្វីដែលគ្មាននរណាអាចធ្វើបាន?*
*៦. តើអ្នកគិតយ៉ាងណាដែលអំពីជីវិតរបស់ស្ត្រីនោះនៅចំពោះព្រះយេស៊ូវ?*

### សេចក្ដីបញ្ចប់

នៅកណ្ដាលចំណោមហ្វូងមនុស្សដ៏ធំ ស្ត្រីបានឈោងទៅចាប់រ៉ូបរបស់ព្រះយេស៊ូវ។ នៅពេលនាងប៉ះអាវវែងរបស់ទ្រង់យើងនាងមានអារម្មណ៍ថាបានជាមកលើរាងកាយរបស់នាង។ នាងបានជាហើយ! សូមស្រមៃមើល ការបានជាសះស្បើយ និងឥរិយាបថដែលនាងអាចមាន។ ព្រះយេស៊ូវមានបន្ទូលថា «កូនស្រីអើយ ជំនឿរបស់នាងបានធ្វើឱ្យនាងជា ចូរចេញទៅដោយសុខសាន្តចុះ»។ ចូរពិចារណាអំពីព្រះបន្ទូលរបស់ទ្រង់។ ទ្រង់បានមានបន្ទូលការនេះ បន្ទាប់ពីការប្រកាសរបស់នាង។ នៅចំពោះមុខបណ្ដាជនដែលចាត់ទុកថា នាងជាស្ត្រីដែលមិនស្អាត ព្រះយេស៊ូវហៅនាងថា កូនស្រី និងផ្ដល់កិត្តិយសចំពោះជំនឿរបស់នាង។ ព្រះយេស៊ូវយកព្រះទ័យទុកដាក់ចំពោះការឈឺចាប់ និងរបួសដែលយើងមាន។ ព្រះអង្គប្រាថ្នាចង់ជួបយើងនៅក្នុងពេលដែលយើងបាក់បែក និងអាម៉ាស់។ ពិចារណាអំពីព្រះយេស៊ូវ។

**ការមើលទៅមុខ**

### ការប្រព្រឹត្តតាម

- តើព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ ថាអាចទុកចិត្តបានយ៉ាងដូចម្ដេច?
- តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនអំពីព្រះជាម្ចាស់យ៉ាងដូចម្ដេច?

### ការអនុគ្គ

- ការអនុវត្តអំពីការនិទានសាច់រឿងដល់គ្នាទៅវិញទៅមក។

### ការចែកចាយ

- តើអ្នកណាដែលអ្នកនឹងចែកចាយរឿងនេះជាមួយ?

### អធិស្ឋាន

- អរគុណព្រះសម្រាប់អ្វីដែលបានរៀន។
- អធិស្ឋានដល់គ្នាទៅវិញទៅមក។
- អធិស្ឋានសម្រាប់អ្នកដទៃនៅក្នុងសហគមន៍។

# មេរៀនទី៧ **ភាពអាម៉ាស់ និងកិត្តិយស**

## ស្ត្រីផិតក្បត់ម្នាក់ទទួលការអត់ទោស (យ៉ូហាន ៨:១-១១)

**ការមើលក្រោយ**

### ការថៃទាំ
- ចែកចាយពីរបៀបដែលអ្នកធ្វើ។
- អនុវត្តតាមដោយសប្បុរស។

### ថ្វាយបង្គំព្រះ
- ថ្វាយបង្គំព្រះជាមួយគ្នាដោយចម្រៀង និងអធិស្ឋាន។

### សាទរភាពស្មោះត្រង់
- លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងភាពជ័យជម្នះ។

### ចាប់យកនិមិត្ត
- លើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីឱ្យមានការប្តូរផ្តាច់ដើរតាមព្រះយេស៊ូវ។

---

**ការមើលទៅលើ**

អ្នកដឹកនាំសាសនានៅសម័យរបស់ព្រះយេស៊ូវ ផ្តោតលើច្បាប់ និងក្រឹត្យវិន័យជាក់លាក់ដែលហៅថា «ក្រឹត្យវិន័យរបស់លោកម៉ូសេ»។ មនុស្សត្រូវតែស្តាប់បង្គាប់ក្រឹត្យវិន័យរបស់លោកម៉ូសេឱ្យបានល្អឥតខ្ចោះ ដើម្បីឱ្យអាចមានទំនាក់ទំនងជាមួយព្រះជាម្ចាស់។ ជាអកុសល គ្មាននរណាអាចធ្វើតាមគ្រប់ទាំងក្រឹត្យវិន័យបានទេ ដោយសារយើងគ្រប់គ្នាមានបញ្ហាដូចគ្នាគឺ៖ អំពើបាប។ អំពើបាបក្នុងភាសាហេព្រើរមានន័យថា «បរាជ័យ» ឬ «ខុសគោលដៅ»។ នៅក្រោមការទាមទាររបស់ក្រឹត្យវិន័យ យើងគ្រប់គ្នាមានកំហុស ហើយស័ក្តិសមនឹងស្លាប់។ បើគ្មានព្រះសង្គ្រោះទេ យើងគ្រប់គ្នានឹងត្រូវវិនាស។ ប៉ុន្តែ ព្រះយេស៊ូវបានយាងមកក្នុងលោកីយ៍នេះ ដើម្បីថ្វាយអង្គទ្រង់ជំនួសយើង ដើម្បីបង់ថ្លៃជួសអំពើបាបរបស់យើង។ នៅក្នុងសាច់រឿងនេះ ស្ត្រីមានបាបម្នាក់ត្រូវបានគេនាំមករកព្រះយេស៊ូវ។ សូមមើលថាតើមានរឿងអ្វីកើតឡើង។

**ជំហានទី១៖ បង្ហាញ។** ចូរទស្សនាមួយវគ្គពីរដង។
**ជំហានទី២៖ ប្រាប់។** ចូរសួរសមាជិកក្រុមឱ្យនិទានវគ្គនៃសាច់រឿងចេញពីពាក្យរបស់គេផ្ទាល់។
**ជំហានទី៣៖ បញ្ចប់។** អនុញ្ញាតឱ្យក្រុមបំពេញចន្លោះនៅក្នុងសាច់រឿងដែលមិនបាននិទាន ឬអាចនិយាយកែតម្រង់ណាមួយ។
**ជំហានទី៤៖ ចូរពិភាក្សា។** ចូរពិភាក្សាសំណួរផ្សេងៗ៖

*១. តើអ្នកចូលចិត្តអ្វីជាងគេនៅក្នុងសាច់រឿង? តើអ្វីទៅដែលធ្វើឱ្យអ្នកចាប់អារម្មណ៍?*
*២. យោងតាមក្រឹត្យវិន័យ ទាំងបុរស និងស្ត្រីដែលគេចាប់បានកំពុងតែប្រព្រឹត្តអំពើផិតក្បត់ គេត្រូវមានទោស ប៉ុន្តែមានតែស្ត្រីត្រូវបានគេនាំមករកព្រះយេស៊ូវ។ ហេតុអ្វីបានជាអ្នកគិតថា មានតែស្ត្រីទេឬដែលត្រូវនាំមកដើម្បីជំនុំជម្រះ?*
*៣.ហេតុអ្វីបានជាការឆ្លើយតបរបស់ព្រះយេស៊ូទៅកាន់ទាំងអ្នកដឹកនាំសាសនា និងស្ត្រីនោះសំខាន់?*
*៤. តើអ្នកគិតយ៉ាងដូចម្តេច ពីអារម្មណ៍របស់ស្ត្រីនោះ ពេលឮព្រះយេស៊ូវមានបន្ទូលថា «ខ្ញុំក៏មិនកាត់ទោសអ្នកដែរ?»*

**ចូរសិក្សាឱ្យកាន់តែស៊ីជម្រៅជាងនេះ (ចូរពិភាក្សាបន្ថែម ប្រសិនបើមានពេល...)**
*៥. ហេតុអ្វីបានជាអ្នកគិតថា ព្រះយេស៊ូវឆ្លើយតបបែបនេះ? តើអ្នកគិតថា ព្រះអង្គចង់ឱ្យពួកគេយល់អំពីអ្វី?*
*៦. ប្រសិនបើអ្នកនៅកន្លែងរបស់អ្នកដឹកនាំសាសនា តើអ្នកអាចនឹងឆ្លើយតបយ៉ាងដូចម្តេចចំពោះចម្លើយរបស់ព្រះយេស៊ូវ?*

ប្រើ QR កូដនេះ ដើម្បីមើលផ្នែកនៃកម្មវិធីនេះជាភាសារបស់អ្នកលើឧបករណ៍ឆ្លាតវៃរបស់អ្នក។

## សេចក្តីបញ្ចប់

ឆ្លុះបញ្ចាំងពីរបៀបដែលព្រះយេស៊ូវឆ្លើយតបទៅកាន់ទាំងស្ត្រី និងអ្នកដឹកនាំសាសនា។ ព្រះអង្គជ្រាបថាគេមិនបាននាំនាងមកកើតចេញពីការអាណិតអាសូរចំពោះនាងឡើយ ប៉ុន្តែដើម្បីនាំឱ្យនាងអាម៉ាស់ និងចង់ឱ្យព្រះអង្គជាប់អន្ទាក់។ ព្រះអង្គបានជ្រើសរើសមិនថ្កោលទោសចំពោះឥរិយាបថរបស់ស្ត្រីនោះ ឬស្របតាមអ្នកដឹកនាំសាសនាឡើយ។ ព្រះអង្គបាននាំពួកគេទៅរកការកាត់ទោសប្រកបដោយប្រាជ្ញា។ ចូរពិចារណាពីរបៀបដែលព្រះហឫទ័យរបស់ព្រះយេស៊ូវ បាននាំទាំងពីភាគីឱ្យប្រែចិត្ត។ ព្រះយេស៊ូវមានអំណាចអត់ទោសបាប ជាអ្វីមួយដែលមានតែព្រះទេអាចធ្វើបាន។ ដោយសារព្រះអង្គគឺជាព្រះ។ នៅពេលយើងជ្រើសរើសដើរតាមព្រះយេស៊ូវ ព្រះអង្គអត់ទោសយើង ហើយប្រទានឱ្យយើងមានជីវិតថ្មីក្នុងទ្រង់។ ពិចារណាអំពីព្រះយេស៊ូវ។

---

**ការមើលទៅមុខ**

### ការប្រព្រឹត្តតាម
- តើព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ ថាអាចទុកចិត្តបានយ៉ាងដូចម្តេច?
- តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនអំពីព្រះជាម្ចាស់យ៉ាងដូចម្តេច?

### ការអនុត្ត
- ការអនុវត្តអំពីការនិទានសាច់រឿងដល់គ្នាទៅវិញទៅមក។

### ការចែកចាយ
- តើអ្នកណាដែលអ្នកនឹងចែកចាយរឿងនេះជាមួយ?

### អធិស្ឋាន
- អរគុណព្រះសម្រាប់អ្វីដែលបានរៀន។
- អធិស្ឋានដល់គ្នាទៅវិញទៅមក។
- អធិស្ឋានសម្រាប់អ្នកដទៃនៅក្នុងសហគមន៍។

# មេរៀនទី៨ ព្រះយេស៊ូវសុគត និងរស់ឡើងវិញ

## នាងម៉ាកដាឡា ពន្យល់អំពីការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ (ម៉ាថាយ ២៧-២៨)

**ការមើលក្រោយ**

### ការថៃទាំ
- ចែកចាយពីរបៀបដែលអ្នកធ្វើ។
- អនុវត្តតាមដោយសប្បុរស

### ថ្វាយបង្គំព្រះ
- ថ្វាយបង្គំព្រះជាមួយគ្នាដោយចម្រៀង និងអធិស្ឋាន

### សាទរភាពស្មោះត្រង់
- លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងភាពជ័យជម្នះ

### ចាប់យកនិមិត្ត
- លើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីឱ្យមានការប្តេជ្ញាចិត្តដើរតាមព្រះយេស៊ូវ

---

**ការមើលទៅលើ**

នៅយប់ដែលព្រះយេស៊ូវសុគត ពួកស្រីៗបានប្រញាប់ទៅផ្ទះដើម្បីរៀបចំកំញាណ និងជ័រល្វីងទេសដើម្បីអប់ព្រះសពព្រះយេស៊ូវ។ នៅថ្ងៃបន្ទាប់ ពួកគេគោរពថ្ងៃសប្ប័ទ ហើយសម្រាប់ជាមួយនឹងសេចក្តីសង្ឃឹមនៃការត្រឡប់មកវិញនៅថ្ងៃបន្ទាប់ទៅកាន់រូបកាយរបស់ព្រះអម្ចាស់ពួកគេ។ ទឹកភ្នែកបានហូរ នៅពេលពួកគេឃើញគេវាយដំ ដែលព្រះយេស៊ូវបានទទួល ហើយដួងចិត្តរបស់ពួកគេឈឺផ្សានៅពេលរូបភាពនៃការសុគតរបស់ទ្រង់ផុសឡើងនៅក្នុងគំនិតរបស់ពួកគេ។ មិត្តភក្តិជាទីស្រឡាញ់របស់ពួកគេ អ្នកការពាររបស់ពួកគេ និងស្តេចរបស់ពួកគេបានសុគត។

**ជំហានទី១៖ បង្ហាញ។** ចូរទស្សនាមួយវគ្គពីរដង។
**ជំហានទី២៖ ប្រាប់។** ចូរសួរសមាជិកក្រុមឱ្យនិទានវគ្គនៃសាច់រឿងចេញពីពាក្យរបស់គេផ្ទាល់។
**ជំហានទី៣៖ បញ្ចប់។** អនុញ្ញាតឱ្យក្រុមបំពេញចន្លោះនៅក្នុងសាច់រឿងដែលមិនបាននិទាន ឬអាចនិយាយកែតម្រង់ណាមួយ។
**ជំហានទី៤៖ ចូរពិភាក្សា។** ចូរពិភាក្សាសំណួរផ្សេងៗ៖

*១. តើអ្នកចូលចិត្តអ្វីជាងគេនៅក្នុងសាច់រឿង? តើអ្វីទៅដែលធ្វើឱ្យអ្នកចាប់អារម្មណ៍?*
*២. ហេតុអ្វីបានជាសំខាន់ ដែលការសុគតរបស់ព្រះយេស៊ូវត្រូវបានប្រាប់ទុកជាមុន តាមរយៈហោរានៅក្នុងគម្ពីរសញ្ញាចាស់?*
*៣. នាងម៉ារានិយាយអំពីបណ្តាសានៃអំពើបាប និងសេចក្តីស្លាប់។ តើការសុគតរបស់ព្រះយេស៊ូវ និងការរស់ឡើងវិញអាចយកឈ្នះការទាំងពីរនេះបានយ៉ាងដូចម្តេច?*
*៤. នាងម៉ារាប្រាប់នាងរីកាថា «នាងជាកូនស្រីគួរឱ្យស្រឡាញ់ណាស់»។ តើការសុគតរបស់ព្រះយេស៊ូវ និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ បង្ហាញថា យើងគឺជាមនុស្សជាទីស្រឡាញ់របស់ព្រះយ៉ាងដូចម្តេច?*

**ចូរសិក្សាឱ្យកាន់តែស៊ីជម្រៅជាងនេះ (ចូរពិភាក្សាបន្ថែម ប្រសិនបើមានពេល...)**
*៥. ហេតុអ្វីបានជាវាសំខាន់ ដែលព្រះយេស៊ូវបានលេចមកឯនាងម៉ារា ហើយនឹងពួកសិស្សពីរបីដងបន្ទាប់ពីព្រះអង្គសុគត?*
*៦. ចូរអានទំនុកតម្កើង ២២ ជាមួយគ្នា។ តើខណាមួយដែលបញ្ជាក់ថាព្រះយេស៊ូវជាព្រះមេស្ស៊ី?*
*៧. មានបីថ្ងៃក្នុងរវាងការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ។ តើអ្នកគិតថា ពួកសិស្សទាំងអស់របស់ព្រះយេស៊ូវមានអារម្មណ៍យ៉ាងដូចម្តេចនៅពេលព្រះយេស៊ូវសុគត?*

ប្រើ QR កូដនេះ ដើម្បីមើលផ្នែកនៃកម្មវិធីនេះជាភាសារបស់អ្នកលើឧបករណ៍ឆ្លាតវៃរបស់អ្នក។

### សេចក្តីបញ្ចប់
ឆ្លុះបញ្ចាំងពីពាក្យរបស់ហោរាអេសាយ «តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់» (អេសាយ ៥៣:៥ ពគប)។ ព្រះយេស៊ូវស្រឡាញ់មនុស្ស។ ព្រះអង្គបានផ្តល់តម្លៃយ៉ាងខ្លាំង និងទាំងស្រុងដែលព្រះអង្គបានទទួលរងបណ្តាសា ទទួលរងការញែកចេញពីព្រះ ហើយបានសុគតជំនួសយើង។ ចូរពិចារណាអំពីក្តីមេត្តា និងអំណាចដែលព្រះយេស៊ូវបានបង្ហាញនៅក្នុងការសុគត និងការរស់ឡើងវិញរបស់ទ្រង់។ ពិចារណាអំពីព្រះយេស៊ូវ។

---

**ការមើលទៅមុខ**

### ការប្រព្រឹត្តតាម
- តើព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ ថាអាចទុកចិត្តបានយ៉ាងដូចម្តេច?
- តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនអំពីព្រះជាម្ចាស់យ៉ាងដូចម្តេច?

### ការអនុត្ត
- ការអនុវត្តអំពីការនិទានសាច់រឿងដល់គ្នាទៅវិញទៅមក។

### ការចែកចាយ
- តើអ្នកណាដែលអ្នកនឹងចែកចាយរឿងនេះជាមួយ?

### អធិស្ឋាន
- អរគុណព្រះសម្រាប់អ្វីដែលបានរៀន។
- អធិស្ឋានដល់គ្នាទៅវិញទៅមក។
- អធិស្ឋានសម្រាប់អ្នកដទៃនៅក្នុងសហគមន៍។

# មេរៀនទី៩ ការស្គាល់ព្រះយេស៊ូវ និងការអត់ទោសរបស់ទ្រង់

## ជំនឿរបស់វីរកា (លូកា ២៤:៣៦-៥០)

**ការមើលក្រោយ**

### ការថែទាំ
• ចែកចាយពីរបៀបដែលអ្នកធ្វើ។
• អនុវត្តតាមដោយសប្បុរស។

### ថ្វាយបង្គំព្រះ
• ថ្វាយបង្គំព្រះជាមួយគ្នាដោយចម្រៀង និងអធិស្ឋាន។

### សាទរភាពស្មោះត្រង់
• លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងភាពជ័យជម្នះ។

### ចាប់យកនិមិត្ត
• លើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីឱ្យមានការប្តូរផ្តាច់ដើរតាមព្រះយេស៊ូវ។

**ការមើលទៅលើ**

យើងឈានមកដល់ទីបញ្ចប់នៃស៊េរីរបស់យើង នៅពេលនាងម៉ារាំលឹកអំពីសាច់រឿងរបស់ព្រះជាម្ចាស់។ ព្រះអង្គទតឃើញ និងស្គាល់យើងម្នាក់ៗ។ ព្រះអង្គគឺជាព្រះសង្គ្រោះ ជាព្រះក្នុងសាច់ឈាម ប្រទានសេរីភាព ហើយប្រោសលោះឱ្យរួចពីចំណង។ ព្រះអង្គមានអំណាចគ្រប់គ្រាន់ក្នុងការប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ ហើយមានសេចក្តីស្រឡាញ់គ្រប់គ្រាន់ដើម្បីជួបមនុស្សដែលមានទុក្ខសោកសៅ និងទុក្ខព្រួយ។ ព្រះអង្គមានគ្រប់ទាំងសិទ្ធិអំណាចក្នុងការអត់ទោស និងប្រោសលោះយើង សូម្បីតែការប្រព្រឹត្តអាក្រក់ និងគួរឱ្យអាម៉ាស់របស់យើងក្តី។ ហើយព្រះបន្ទូលរបស់ទ្រង់គឺជាទីបញ្ចប់ សូម្បីតែស្លាប់ក្តី។ សូមមើល ខណៈដែលវីរការឆ្លើយតបចំពោះព្រះយេស៊ូវ។

**ជំហានទី១៖ បង្ហាញ។** ចូរទស្សនាមួយវគ្គពីរដង។
**ជំហានទី២៖ ប្រាប់។** ចូរសួរសមាជិកក្រុមឱ្យនិទានវគ្គនៃសាច់រឿងចេញពីពាក្យរបស់គេផ្ទាល់។
**ជំហានទី៣៖ បញ្ចប់។** អនុញ្ញាតឱ្យក្រុមបំពេញចន្លោះនៅក្នុងសាច់រឿងដែលមិនបាននិទាន ឬអាចនិយាយកែតម្រង់ណាមួយ។
**ជំហានទី៤៖ ចូរពិភាក្សា។** ចូរពិភាក្សាសំណួរផ្សេងៗ៖

*១. តើអ្នកចូលចិត្តអ្វីជាងគេនៅក្នុងសាច់រឿង? តើអ្វីទៅដែលធ្វើឱ្យអ្នកចាប់អារម្មណ៍?*
*២. តើចរិតលក្ខណៈអ្វីអំពីព្រះយេស៊ូវដែលមានន័យបំផុតចំពោះអ្នក?*
*៣. តើអំពើបាបរបស់យើងត្រូវបានផ្សះផ្សាជាមួយព្រះបានយ៉ាងដូចម្តេច?*
*៤. នាងវីរកាមិនប្រាដកថានាងអាចទទួលបានការអត់ទោស។ ហេតុអ្វីបានជាសំខាន់ ដែលនាងត្រូវទុកចិត្តលើព្រះបន្ទូលព្រះទាំងស្រុង ហើយការអត់ទោសរបស់ទ្រង់ មិនមែនលើអ្វីដែលនាងមានអារម្មណ៍នោះទេ ឬឥរិយាបទរបស់នាងនោះទេ។*
*៥. តើមាននរណាក្នុងចំណោមអ្នកអធិស្ឋានជាមួយនាងវីរកាដែរទេ? តើមាននរណាចង់អធិស្ឋានទេ?*

**ចូរសិក្សាឱ្យកាន់តែស៊ីជម្រៅជាងនេះ (ចូរពិភាក្សាបន្ថែម ប្រសិនបើមានពេល...)**
*៦. ហេតុអ្វីបានវាសំខាន់ សម្រាប់អ្នកដើរតាមព្រះយេស៊ូវដើម្បីឱ្យប្រាកដនៅក្នុងសេចក្តីសង្គ្រោះរបស់ពួកគេ?*
*៧. តើអ្នកអាចមានការស្ទាក់ស្ទើរដូចវិរកាដែរទេ? ប្រសិនបើ មាន សូមចែកចាយការស្ទាក់ស្ទើរ ឬបារម្ភរបស់អ្នក។*
*៨. តើអ្នកកំពុងពិចារណានឹងថ្វាយជីវិតរបស់អ្នកទៅព្រះយេស៊ូវនៅនៅពេលនេះ?*

ប្រើ QR កូដនេះ ដើម្បីមើលផ្នែកនៃកម្មវិធីនេះជាភាសារបស់អ្នកលើឧបករណ៍ឆ្លាតវៃរបស់អ្នក។

### សេចក្តីបញ្ចប់
នៅក្នុងវគ្គនេះ យើងមើលនាងវីរកាសម្រេចចិត្តដើរតាមព្រះយេស៊ូវ។ ចូរពិចារណាអំពីផលប៉ះពាល់នៃការដើរតាមទ្រង់ និងអ្វីដែលសំខាន់សម្រាប់ជីវិតរបស់អ្នក។ តើអ្នកប្រាថ្នាចង់មានសេរីភាពពីអំពើបាបដែរឬទេ? ទទួលការអត់ទោស និងប្រោសលោះដែរឬទេ? ត្រូវបានព្រះទតឃើញ និងស្គាល់ដែរឬទេ? ក្នុងការមាននរណាម្នាក់ដែលគួរឱ្យទុកចិត្តដែរឬទេ? មានជំនឿស្មោះត្រង់ និងសោកស្តាយចំពោះអំពើបាបទាំងនោះគឺជាអ្វីដែលព្រះយេស៊ូវចង់បានពីយើង។ នៅពេលអ្នកចូលទៅរកទ្រង់ អ្នកអាចប្រាកដថា ព្រះអង្គនឹងទតឃើញ ហើយឱ្យតម្លៃចំពោះជំនឿរបស់អ្នកឥឡូវនេះ និងជារៀងរហូត។ នៅពេលនេះ អ្នកបានពិចារណាអំពីព្រះយេស៊ូវ នេះគឺជាពេលវេលាសម្រាប់ការសម្រេចចិត្តហើយ។ តើអ្នកដើរតាមទ្រង់ឬទេ?

** កំណត់សម្គាល់អ្នកដឹកនាំ៖ វាមានសារសំខាន់ក្នុងការផ្តល់ឱកាសដល់នរណាម្នាក់ដើម្បីសម្រេចចិត្តដើរតាមព្រះយេស៊ូវ។ សូមឱ្យប្រាកដ ហើយសួរក្រុមថា «តើមាននរណាអធិស្ឋានជាមួយវីរកាទេ? តើមាននរណាចង់អធិស្ឋានដែរទេ?» ប្រសិនបើ អាចធ្វើបាន សូមឈោងចាប់ស្ត្រីផ្សេងៗទៀតនៅក្រៅក្រុមផងដែរ។*

**ការមើលទៅមុខ**

### ការប្រព្រឹត្តតាម
- តើព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ ថាអាចទុកចិត្តបានយ៉ាងដូចម្តេច?
- តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនអំពីព្រះជាម្ចាស់យ៉ាងដូចម្តេច?

### ការអនុវត្ត
- ការអនុវត្តអំពីការនិទានសាច់រឿងដល់គ្នាទៅវិញទៅមក។

### ការចែកចាយ
- តើអ្នកណាដែលអ្នកនឹងចែកចាយរឿងនេះជាមួយ?

### អធិស្ឋាន
- អរគុណព្រះសម្រាប់អ្វីដែលបានរៀន។
- អធិស្ឋានដល់គ្នាទៅវិញទៅមក។
- អធិស្ឋានសម្រាប់អ្នកដទៃនៅក្នុងសហគមន៍។

# មេរៀនទី១០ ការរស់នៅជាមួយព្រះយេស៊ូវ

## ការរស់នៅក្នុងជីវិតគ្រីស្ទបរិស័ទ (ម៉ាថាយ ២៨:១៨-២០)

**ការមើលក្រោយ**

### ការថែទាំ
• ចែកចាយពីរបៀបដែលអ្នកធ្វើ។
• អនុវត្តតាមដោយសប្បុរស។

### ថ្វាយបង្គំព្រះ
• ថ្វាយបង្គំព្រះជាមួយគ្នាដោយចម្រៀង និងអធិស្ឋាន។

### សាទរភាពស្មោះត្រង់
• លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងភាពជ័យជម្នះ។

### ចាប់យកនិមិត្ត
• លើកទឹកចិត្តគ្នាទៅវិញទៅមក ដើម្បីឱ្យមានការប្តូរផ្តាច់ដើរតាមព្រះយេស៊ូវ។

---

**ការមើលទៅលើ**

ការដើរតាមព្រះយេស៊ូវមានន័យថា អ្នកនឹងបានទទួលការផ្លាស់ប្រែ ដូចនាងម៉ារាបានផ្លាស់ប្រែដែរ។ ព្រះអង្គហៅយើងទៅកាន់អ្វីដែលប្រសើរជាង រស់នៅចេញពីអត្តសញ្ញាណរបស់ទ្រង់ និងមានកិត្តិយស សេចក្តីសង្ឃឹម និងសេចក្តីល្អរបស់ទ្រង់។ ព្រះអង្គហៅយើងឱ្យទុកចិត្តលើព្រះអង្គ លើព្រះបន្ទូល និងសេចក្តីបង្គាប់របស់ទ្រង់ ដោយដឹងថា ព្រះអង្គជាព្រះរបស់យើង។ ព្រះអង្គត្រាស់ហៅយើងឱ្យសម្រាកដោយសុវត្ថិភាពក្នុងទ្រង់ ដោយដឹងថា ព្រះអង្គជ្រាប និងយល់គ្រប់ទាំងផ្នែករបស់យើង។

**ជំហានទី១៖ បង្ហាញ។** ចូរទស្សនាមួយវគ្គពីរដង។
**ជំហានទី២៖ ប្រាប់។** ចូរសួរសមាជិកក្រុមឱ្យនិទានវគ្គនៃសាច់រឿងចេញពីពាក្យរបស់គេផ្ទាល់។
**ជំហានទី៣៖ បញ្ចប់។** អនុញ្ញាតឱ្យក្រុមបំពេញចន្លោះនៅក្នុងសាច់រឿងដែលមិនបាននិទាន ឬអាចនិយាយកែតម្រង់ណាមួយ។
**ជំហានទី៤៖ ចូរពិភាក្សា។** ចូរពិភាក្សាសំណួរផ្សេងៗ៖

*១. តើអ្នកចូលចិត្តអ្វីជាងគេនៅក្នុងសាច់រឿង? តើអ្វីទៅដែលធ្វើឱ្យអ្នកចាប់អារម្មណ៍?*
*២. តើការដើរតាមព្រះយេស៊ូវមានលក្ខណៈដូចម្តេច?*
*៣. តើពាក្យចុងក្រោយរបស់ព្រះយេស៊ូវប៉ះពាល់អ្នកយ៉ាងដូចម្តេច?*
*៤. តើអ្នកចង់ឱ្យព្រះយេស៊ូវផ្លាស់ប្រែនៅក្នុងជីវិតរបស់អ្នកអ្វីខ្លះ?*

ប្រើ QR កូដនេះ ដើម្បីមើលផ្នែកនៃកម្មវិធីនេះជាភាសារបស់អ្នកលើឧបករណ៍ឆ្លាតវៃរបស់អ្នក។

**ចូរសិក្សាឱ្យកាន់តែស៊ីជម្រៅជាងនេះ (ចូរពិភាក្សាបន្ថែម ប្រសិនបើមានពេល...)**
*៥. តើអ្វីធ្វើឱ្យអ្នកភ័យខ្លាចបំផុត អំពីការអនុញ្ញាឱ្យព្រះយេស៊ូវបំផ្លាស់បំប្រែជីវិតរបស់អ្នក?*
*៦. តើព្រះបន្ទូលរបស់ព្រះយេស៊ូវលើកទឹកចិត្តអ្នកយ៉ាងណា?*

## សេចក្តីបញ្ចប់

ឆ្លុះបញ្ចាំងទៅលើគន្លឹះបីសំខាន់ៗអំពីព្រះបន្ទូលចុងក្រោយរបស់ព្រះយេស៊ូវមានបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់។ ព្រះយេស៊ូវប្រកាសថា ព្រះអង្គបានប្រទានគ្រប់ទាំងសិទ្ធិអំណាចនៅលើស្ថានសួគ៌ និងផែនដី។ ព្រះអង្គបានបង្គាប់យើងឱ្យចេញទៅបង្កើតសិស្ស បង្រៀនពួកគេនូវអ្វីៗទាំងអស់ដែលព្រះអង្គបានបង្គាប់។ ហើយព្រះអង្គបានធានាយើងថា ព្រះអង្គនឹងគង់នៅជាមួយយើង រហូតដល់ចុងបំផុតនៃផែនដីផង។ ចូរពិចារណា តើវាសំខាន់សម្រាប់ជីវិតរបស់អ្នកក្នុងការឆ្លុះបញ្ចាំងការប្រកាសចុងក្រោយ សេចក្តីបង្គាប់ និងការធានាអះអាងរបស់ព្រះយេស៊ូវ។ ពិចារណាអំពីព្រះយេស៊ូវ។

មិនថាអ្នក រួចរាល់ ឬអត់ ក្នុងការដើរតាមព្រះយេស៊ូវទេ តើអ្នកចង់បន្តរៀនអំពីទ្រង់ និងរៀនពីរបៀបដែលអ្នកអាចដើរតាមទ្រង់ដែរឬទេ? មានឱកាសជាច្រើនសម្រាប់អ្នក ដើម្បីបន្តរៀន និងលូតលាស់នៅក្នុងដំណើរជីវិតខាងវិញ្ញាណរបស់អ្នកជាមួយគ្នា។ ទោះបីជានេះគឺជាការបញ្ចប់វគ្គនៃ *ពិចារណាអំពីព្រះយេស៊ូវ* ក្តី មានជំហានពីរបីទៀតដែលអ្នកអាចបោះទៅបន្ទាប់។ ចូរពិភាក្សាជាមួយគ្នា តើអ្វីជាជំហានបន្ទាប់ ដែលចង់បោះសម្រាប់អ្នកគ្រប់គ្នា។ *វីកា និង ការស្គាល់ព្រះយេស៊ូវ* គឺជាផលិតកម្មខ្សែភាពយន្តរបស់ព្រះយេស៊ូវដែលណែនាំសម្រាប់ជំហានបន្ទាប់។ ព័ត៌មានបន្ថែមគឺត្រូវបានបូកបន្ថែមនៅក្នុងកម្មវិធីទាំងនេះនៅក្នុងជំហានទីបួននៃមគ្គុទេសក៍អ្នកដឹកនាំ។ **អ្នកប្រហែលជាចង់ចែកចាយអ្វីដែលអ្នកបានរៀនជាមួយអ្នកដទៃទៀត ហើយចាប់ផ្តើមក្រុមរបស់អ្នកផ្ទាល់គឺ *ពិចារណាអំពីព្រះយេស៊ូវ។* សួរអ្នកដឹកនាំក្រុមរបស់អ្នក សម្រាប់យោបល់ និងការគាំទ្រ ប្រសិនបើ ការនេះវាស័ក្តិសមនឹងជំហានបន្ទាប់របស់អ្នក។**

---

**ការមើលទៅមុខ**

### ការប្រព្រឹត្តតាម
- តើព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ ថាអាចទុកចិត្តបានយ៉ាងដូចម្តេច?
- តើអ្នកនឹងអនុវត្តអ្វីដែលអ្នកបានរៀនអំពីព្រះជាម្ចាស់យ៉ាងដូចម្តេច?

### ការអនុត្ត
- ការអនុវត្តអំពីការនិទានសាច់រឿងដល់គ្នាទៅវិញទៅមក។

### ការចែកចាយ
- តើអ្នកណាដែលអ្នកនឹងចែកចាយរឿងនេះជាមួយ?

### អធិស្ឋាន
- អរគុណព្រះសម្រាប់អ្វីដែលបានរៀន។
- អធិស្ឋានដល់គ្នាទៅវិញទៅមក។
- អធិស្ឋានសម្រាប់អ្នកដទៃនៅក្នុងសហគមន៍។

# ពិចារណាអំពីព្រះយេស៊ូវ

## យុទ្ធសាស្ត្រ១០សប្ដាហ៍សម្រាប់ក្រុមតូចនៅក្នុងសហគមន៍

Jesus Film Project®
A Cru Ministry